Java

Programming

Lesson

មាតិកា

មេរៀនទី ៤

ការប្រើប្រាស់ *ARRAY*

មេរៀនទី ៥

ការប្រើប្រាស់ Object **នៅក្នុង** Java

មេរៀនទី ៦

អំពី Inheritance

មេរៀនទី ៧

អំពី *Package* និង *Interface*

មេរៀនទី ៨

ការប្រើ *Exception*

មេរៀនទី ៩

String និង *Collections*

មេរៀនទី ១០

អំពីការប្រើប្រាស់ *Events*

មេរៀនទី ១១

AWT Controls, Layout Managers និង Menus

មេរៀនទី ១២

អំពី *Applet*

មេរៀនទី ១៣

អំពីការប្រើប្រាស់ *Graphics*

មេរៀនទី ១

ការណែនាំឲ្យស្គាល់ Java
Introduction to Java

១.ប្រវត្តិនៃ Java

Java គឺជាភាសាមួយដែលត្រូវបានបង្កើតឡើងដោយលោក James Gosling ។ គាត់ជាបុគ្គលិកធ្វើការនៅក្រុមហ៊ុន Sun Microsystems នៅក្នុងគំរោងស្រាវជ្រាវមួយឈ្មោះថា Green Project នៅឆ្នាំ ១៩៩១។ គម្រោងនេះបានប្រើភាសាមួយដែលមានមូលដ្ឋានឈរលើភាសា C និង C++ ។ ដំបូងឡើយភាសានេះឈ្មោះថា Oak បន្ទាប់ពីលោកបានឃើញដើម Oak តាមរយៈបង្អួចការិយាល័យរបស់គាត់ក្នុងក្រុមហ៊ុន Sun។ តែឈ្មោះនេះត្រូវបានប្តូរតាមសំណើរបស់មិត្តរួមការងាររបស់គាត់ទៅជា Java បន្ទាប់ពីគាត់ត្រឡប់ពីហាងកាហ្វេ ហើយក៏មានឈ្មោះថា Java រហូតមកដល់សព្វថ្ងៃនេះ។

ការងាររបស់ Green Project មានការលំបាកយ៉ាងខ្លាំងជាហេតុធ្វើអោយកិច្ចព្រមព្រៀមសំខាន់មួយរបស់ក្រុមហ៊ុន Sun ត្រូវបានប្រគល់អោយក្រុមហ៊ុនដទៃ។ ការងាររបស់ Green Project ស្ទើតែដួលរលំទៅហើយ តែសំណាងល្អនៅឆ្នាំ ១៩៩៣ World Wide Web បានលេចធ្លោឡើងបានធ្វើអោយអ្នកធ្វើការនៅក្រុមហ៊ុន Sun មើលឃើញយ៉ាងច្បាស់ពីអនុភាពនៃការប្រើ Java ដើម្បីបង្កើត Web Page វាបានធ្វើអោយគម្រោងនេះដើរសារជាថ្មីវិញ។

២. Version របស់ Java

-នៅឆ្នាំ ១៩៩៥ Java 1.0 ជា Version មួយមានលក្ខណៈប្រសើរសម្រាប់ប្រើលើ World Wide Web វាមាន Packages ចំនួន៨ ដោយមាន Classes ចំនួន ២១២។

-នៅឆ្នាំ ១៩៩៧ java 1.1 ជា Version មួយដែលបានបង្កើនដល់ភាសានូវមធ្យោបាយសម្រាប់បង្កើត និងប្រើ User Interface ជាពិសេសវាបានកែលំអលើផ្នែកការប្រើ events, inner class។ វាមាន Packages ចំនួន ២៣ ដោយមាន Classes ចំនួន ៥០៤។ លើសពីនេះ swing package បានកែលំអលើផ្នែកក្រាហ្វិចយ៉ាងលើសលប់ ប៉ុន្តែនៅមិនទាន់បានបញ្ចូលចំណុចសំខាន់ៗនៃភាសានៅឡើយ។

-នៅឆ្នាំ ១៩៩៩ Java 1.2 (ហៅថា Java 2) ជា Version មួយដែលបង្កើនដល់ភាសានូវមធ្យោបាយដ៏សំបូរបែបច្រើនជាងភាសាសំនេរកម្មវិធីផ្សេង២ទៀត។ វាមាន Packages ចំនួន ៥៩ ដោយមាន Classes ចំនួន ១៥២០ ។ វាបានបញ្ចូលនូវ Code និង Tools ដោយ Software Development Kit (SDK) ។ Java Foundation Classes (JFC) ដែលមានមូលដ្ឋានលើ Swing សម្រាប់កែលំអក្រាហ្វិច និង User Interfaces ក៏បានបញ្ចូលនូវចំនុចសំខាន់ៗនៃភាសាផងដែរ។ លើសពីនេះ Collection API ក៏បានបញ្ចូលដើម្បីឲ្យគេអាចប្រើ lists, sets និង hash maps។

-ឆ្នាំ ២០០០ Java 1.3 បានបង្កើតឡើង និងមាន Packages ចំនួន៧៦ ដោយមាន Classes ចំនួន ១៨៤២ ។ វាបានបង្កើនមុខងារឲ្យ Hotspot virtual machine ។

-ឆ្នាំ ២០០២ Java 1.4 បានបង្កើតឡើង និងមាន Packages ចំនួន ១៣៥ ដោយមាន Classes ចំនួន ២៩៩១ ។ វាបានកែលំអលើផ្នែក I/O និងអាចប្រើ XML...។

-ឆ្នាំ ២០០៤ Java 1.5 បានបង្កើតឡើង និងមាន Packages ចំនួន ១៦៥ ដោយមាន Classes ចំនួនច្រើនជាង ៣០០ ។ វាបានកែលំអលើផ្នែក Multithreaded និងទម្រង់ Output, metadata...។

-ឆ្នាំបន្តបន្ទាប់មកទៀតមាន Java 1.6 ត្រូវបានបង្កើតឡើងដែរ និងមាន Packages ចំនួន ២០០ ។

៣. <u>លក្ខណៈរបស់ Java</u>

គេថា Java មានលក្ខណៈ: Simple, Object Oriented, Statically Typed, Compiled and Interpreted, Architecture Neutral and Portable, Multithreaded, Garbage Collected, robust, Secure, Built-in Networking and Extensible ។

-Simple : អ្នកបង្កើត Java បានលុបបំបាត់ចោលនូវលក្ខណៈមិនចាំបាច់មួយចំនួនរបស់ភាសាសំនេរកម្មវិធី ដូចជា Java មិនប្រើ Pointers, Structures, Unions, Templates, Header file ឬ Multiple Inheritance ជាដើម។

-Object Oriented : ដូចនឹងភាសា C ឬ C++ ដែរ គឺប្រើ Classes ដើម្បីរៀបចំ Code ឲ្យទៅជាសំនុំមួយត្រឹមត្រូវ ហើយវាបង្កើត Objects តាមរយៈ Classes ។ Class របស់ Java អាចទទួលលក្ខណៈពី Class មួយផ្សេងទៀត។ ប៉ុន្តែ Class មួយមិនអាចទទួលលក្ខណៈពី Classes ច្រើនបានឡើយ។

-Statically Typed : គ្រប់ Object ទាំងអស់មុនពេលប្រើប្រាស់នៅក្នុងកម្មវិធីមួយ ដាច់ខាតត្រូវតែប្រកាសវាជាមុនសិន។ លក្ខណៈនេះអាចធ្វើឲ្យ Compiler របស់ Java រកឃើញនូវទីតាំង និងប្រាប់ឲ្យដឹងនូវប្រភេទទិន្នន័យដែលមិនត្រូវគ្នា។

-Compiled and Interpreted : មុននឹងយើងអាចដំណើរការកម្មវិធីមួយដែលសរសេរឡើងជាភាសា Java បាននោះលុះត្រាតែយើង Compile វាតាមរយៈ Compiler របស់វាជាមុនសិន។ នៅពេល Compile រួចដោយជោគជ័យ វានឹងបង្កើតបាន File មួយផ្សេងទៀតប្រភេទជា Byte-Code ដែលស្រដៀងគ្នាទៅនឹង Machine-code ហើយវាអាចដំណើរការក្នុងប្រព័ន្ធ Computer ដោយមាន Interpreter របស់ Java។ Interpreter ជាអ្នកបកប្រែពី Byte-code ទៅជាពាក្យបញ្ជាប្រភេទ machine-code ។ ហេតុនេះហើយបានជាគេថា Java មានលក្ខណៈ: Compiled and Interpreted ។

-Architecture Neutral and Portable: ដោយសារកម្មវិធីដែលសរសេរឡើងដោយ Java ត្រូវបាន Compiled ជាទម្រង់ Byte-code ដែលមានលក្ខណៈមិនអាស្រ័យនឹងទម្រង់ខាងក្នុងរបស់ Computer ជាហេតុធ្វើឲ្យកម្មវិធីដែលសរសេរឡើងដោយ Java អាចដំណើរការលើប្រព័ន្ធណាមួយក៏បាន(មិនប្រកាន់ plate form) ។

-Multithreaded: Java មាន threads សម្រាប់អនុវត្តធ្វើការប្រតិបត្តិការងារច្រើនក្នុងពេលតែមួយបាន។

-Garbage Collected : Java បានធ្វើការប្រមូលនូវអ្វីៗដែលមិនចាំបាច់ លុបចោលពី Memory ដោយខ្លួនឯង មិនចាំបាច់សរសេរ code ដើម្បីលុប Object ដែលមិនប្រើនោះទេ(បានន័យថា Variables ឬ Objects ណាដែលឈប់ប្រើហើយវានឹងលុបចោលដោយខ្លួនឯង ជួយសម្រួលដល់អ្នកសរសេរកម្មវិធីមិនព្រួយបារម្ភណ៍ពីការខ្វះខាត Memory ដោយសារ Objects មិនបានការណ៍នោះឡើយ)។

-Robust : ដោយសារ Interpreter របស់ Java ពិនិត្យគ្រប់ដំណើរការចូលទៅក្នុងប្រព័ន្ធទាំងអស់របស់កម្មវិធី ជាហេតុធ្វើឲ្យកម្មវិធីដែលសរសេរដោយ Java មិនប៉ះពាល់ដល់ប្រព័ន្ធ Computer ឡើយ។ កាលណាវាមាន Error វានឹងបង្កើតជា Exception។

-Secure : វាមិនគ្រាន់តែត្រួតពិនិត្យរាល់ដំណើរការចូលក្នុង Memory ប៉ុណ្ណោះទេ វាថែមទាំងធានាមិនឆ្លង Virus នៅពេលកំពុងដំណើរការកម្មវិធីទៀតផង ព្រោះវាមិនប្រើ Pointer ធ្វើឲ្យ Virus មិនអាចចូលទៅកាន់ Memory នៃប្រព័ន្ធ Computer បានឡើយ។

- Built-in Networking : Java បានបង្កើតឲ្យមានការប្រើលក្ខណៈជាបណ្តាញ ដោយនាំមកនូវ Classes ជាច្រើនសម្រាប់បង្កើតទំនាក់ទំនងជាមួយ Internet ។

-Extensible : Java អាចឲ្យប្រើនូវ native methods ដែលជា Functions ដែលសរសេរឡើងក្នុងភាសាផ្សេងៗ ដូចជា C ឬ C++ ជាដើម។ លក្ខណៈនេះវាធ្វើឲ្យអ្នកសរសេរកម្មវិធីសរសេរ function ដែលអាចប្រតិបត្តិការបានលឿនជាងការសរសេរ functions នៅក្នុង Java។ Native Methods ដំណើរការភ្ជាប់ទៅនឹងកម្មវិធី Java មានន័យថាវាបញ្ចូលជាមួយកម្មវិធីនៅក្នុងពេលដំណើរការកម្មវិធី។ នៅពេលដែល Java ត្រូវបានជម្រុញលើបញ្ហាល្បឿននោះ Native Methods ប្រហែលជាឥតត្រូវការទៀតឡើយ។ លើសពីនេះ Java អាចឲ្យគេប្រើជាមួយនឹងកម្មវិធីផ្សេងទៀតបាន ដូចជា Microsoft Access និង HTML ជាដើម។

៤. Java applications និង Java applets

គេអាចបង្កើតកម្មវិធីពី Java តាមពីរបៀបគឺតាមរយៈ Java applications ឬក៏តាម Java applets។

-Java Applications : គឺជាកម្មវិធីមួយដែលអាចដំណើរការនៅលើម៉ាស៊ីន Computer មួយ ក្រោមដំណើរការរបស់ប្រព័ន្ធ Computer នោះ។

-Java applets : គឺជាកម្មវិធីដែលអាចដំណើរការនៅលើ Internet វាអាចដំណើរការនៅលើ web browsers ណាក៏បាន វាអាចប្រើរូបភាព សំឡេង ឬក៏ជាវីដេអូ (video clip)។ Applets មិនគ្រាន់តែជាកម្មវិធីសម្រាប់ធ្វើឲ្យរូបភាពមានចលនា និង សម្លេងនោះទេ(Multimedia)ថែមទាំងជាកម្មវិធីមានលក្ខណៈឆ្លាតដែលអាចឲ្យអ្នកប្រើប្រាស់មានសកម្មភាពទៅវិញទៅមកក្នុងការបញ្ចូលទិន្នន័យនិងប្តូរទិន្នន័យទៀតផង។

៥. ការចាប់ផ្តើមដំណើរការកម្មវិធី

```
/* This is the first example java program.
   Save file as "Example.java" */
class Example{
```

```
//your program begins with a call to main()
public static void main(String[] arg){
        System.out.println("This a simple Java Program");
}
}
```

- ដើម្បីដំណើរការកម្មវិធីនេះជំហានទី១ យើងត្រូវ Compile វាសិនដោយអនុវត្តដូចខាងក្រោម៖

```
C:\JDK1.6\BIN\javac  Example.java
```

ចំពោះ (JDK1.6) អាស្រ័យទៅតាម Version របស់ Java។ ក្រោមពី Compile ហើយវាបានបង្កើត File មួយ ដែលមានប្រភេទជា byte-code ដែលមានឈ្មោះដូចនឹងឈ្មោះ class ហើយមាន extension (.class) គឺ Example.class ដែលជា File សម្រាប់ដំណើរការ។

- ជំហានទី ២ យើងត្រូវអនុវត្តដូចតទៅ៖

```
C:\JDK1.6\BIN\java  Example
```

ដោយមិនមាន extension (.java ឬ .class) ឡើយ។

End

មេរៀនទី ២

ប្រភេទទិន្នន័យ អញ្ញាត និងសញ្ញាណនព្វន្ត

Data Type, Variable and Arithmetic Operators

Java គឺជាភាសាមួយដែលមានលក្ខណៈ Statically typed បានន័យថារាល់អញ្ញាត កន្សោម ត្រូវបានកំណត់ប្រភេទទិន្នន័យច្បាស់លាស់មុនពេលប្រើប្រាស់ កត្តានេះជាហេតុធ្វើឲ្យ java មានភាពរឹងមាំ និងមានសុវត្ថិភាព។ នៅពេលដែលយើងហៅ អញ្ញាត ឬកន្សោមមកប្រើ compiler java បានត្រួតពិនិត្យរួចជាស្រេចចំពោះភាពត្រូវគ្នានៃទិន្នន័យ កាលណាវាមានប្រភេទទិន្នន័យមិនត្រូវគ្នា វានឹងមាន Error កើតឡើង ហើយវានឹងបញ្ឈប់ការបំលែងពី Source file ទៅជា file ដែលមាន extension (.class) ដែលជា file សម្រាប់ដំណើរការ។

១. ប្រភេទទិន្នន័យ Simple

ភាសា Java មានប្រភេទទិន្នន័យ Simple ចំនួន ៨ គឺ៖ byte, short , int, long, char, float, double និង boolean ។ដែលប្រភេទទាំងនេះត្រូវបានគេបែងចែកជា ៤ ក្រុមធំៗទៀតគឺ៖

-Integers : ក្នុងក្រុមប្រភេទ Integer នេះរួមមាន byte, short, int និង long ដែលជាប្រភេទទិន្នន័យចំនួនគត់។

-Floating point : ក្នុងក្រុមប្រភេទ Floating-point នេះរួមមាន float និង double ដែលជាប្រភេទទិន្នន័យចំនួនទសភាគ។

-Characters : ក្នុងក្រុមប្រភេទ Character នេះមានតែ char តែមួយគត់ ដែលជាតួអក្សរ សញ្ញាពិសេសផ្សេងៗ លេខមួយតួៗ ។

-Boolean : ក្នុងក្រុមប្រភេទ Boolean នេះក៏មានតែ boolean តែមួយគត់ដែរ ដែលតាងឲ្យ ពិត ឬមិនពិត(true ឬ false)។

២. អញ្ញាត (Variable)

នៅក្នុង Java programming មុននឹងយើងប្រើប្រាស់អញ្ញាតមួយបានលុះត្រាតែយើងប្រកាស់វាជាមុនសិន។ ការប្រកាសអញ្ញាតមួយមានទំរង់ដូចខាងក្រោម៖

```
type    identifier  [= value];
type    identifier [=value], identifier [=value],……;
```

- type គឺជាប្រភេទទិន្នន័យមួយរបស់ Java ឬជាឈ្មោះរបស់ class ឬអាចជា Interface។
- identifier គឺជាឈ្មោះរបស់ Variable ។ នៅក្នុង Java យើងអាចកំណត់តម្លៃតំបូងទៅឲ្យអញ្ញាតមួយ ដោយដាក់សញ្ញាស្មើ (=) និងតម្លៃដែលយើងចង់កំណត់។

<u>កំណត់ចំណាំ</u>៖ ការកំណត់ឈ្មោះរបស់អញ្ញាតមួយ មានលក្ខណៈដូចនឹងភាសា C ឬ C++ ដែរ។

ឧទាហរណ៍៖

int x, y, z; //ប្រកាសអញ្ញាតប្រភេទ Integer ចំនួនបីគឺ x, y និង z ដែលគ្មានការកំណត់តម្លៃដំបូង។

int x=9, y=1;// ប្រកាសអញ្ញាតប្រភេទ Integer ចំនួនពីរដោយ x មានតម្លៃ =៩ និង y មានតម្លៃ=១

២.១ ការកំណត់តម្លៃដែលមានលក្ខណៈប្រែប្រួល(Dynamic initialization)

Java Programming អាចអនុញ្ញាតឲ្យយើងធ្វើការកំណត់តម្លៃសដំបូងដែលមានលក្ខណៈប្រែប្រួលបាន ដោយប្រើកន្សោមលេខត្រឹមត្រូវណាមួយកំណត់ទៅឲ្យអញ្ញាតនៅពេលយើងប្រកាសវា។

ឧទាហរណ៍៖

```
class Demo{
public static void main(String[] agr){
        float a=2.0, b=3.0;
                double  c=Math.sqrt(a*a+b*b);
                System.out.println("The value of C = " + c);
        }
}
```

២.២ Scope និងLifetime របស់អញ្ញាត

ការប្រកាសអញ្ញាតនៅក្នុងកម្មវិធី Java គឺយើងអាចប្រកាសនៅក្នុង Block "{...}" ណាមួយក៏បាន នៅក្នុងកម្មវិធីជាច្រើនគេបានកំណត់ Scope របស់អញ្ញាតជាពីរគឺ៖ Global និង Local តែនៅក្នុងកម្មវិធី Java វិញកំណត់ទំហំ Scope ជាពីរដែរគឺ Class និងMethod។ Scope របស់អញ្ញាតមួយ អាចនៅក្នុង Scope មួយទៀត។

ឧទាហរណ៍៖

```
class DemoScope{
public static void main(String[] arg){
        int x;
        x=9;
        if (x==9){
                int y=10;
                System.out.println("x and y " + x + " "+ y);
                x= y * 3;
        }
        //y=30 ;                    //Error Because y here unknown out of y scope
        System.out.println("Value of x= " + x);
}
}
```

២.៣ ការបំលែងប្រភេទទិន្នន័យ(Type conversion and Casting)

នៅក្នុង Java វាមានលក្ខណៈពិសេសមួយចំនួនដូចជា៖

-កាលណាអញ្ញាតមួយ ត្រូវផ្ទេរតំលៃទៅឲ្យអញ្ញាតមួយទៀតមានប្រភេទទិន្នន័យដូចគ្នា វាធ្វើដោយស្វ័យប្រវត្តិ។

-ប្រភេទទិន្នន័យនៃអញ្ញាតអង្គខាងឆ្វេងធំជាងអង្គខាងស្តាំវាធ្វើដោយស្វ័យប្រវត្តិ។

-ប៉ុន្តែដើម្បីបំលែងប្រភេទទិន្នន័យដែលមិនត្រូវគ្នាយើងត្រូវប្រើតាមទំរង់ដូចខាងក្រោម៖

(target) value;

ឧទាហរណ៍៖ ដើម្បីបោះលែងពីប្រភេទ integer ទៅ boolean យើងត្រូវសរសេរដូចខាងក្រោម៖

```
int x;
byte b;
b=(byte) x;
```

```
/* Demonstration  conversion between integer to byte ,double to byte and double to integer*/
class DemoConversion{
    public static void main (String[] agr){
    byte b;
    int i=234;
    double d=123.456;
    b=(byte) i;
    System.out.println(" Conversion of integer to byte. ");
    System.out.println(" i  and b " + i  + " " + b);
    b=(byte) d;
    System.out.println(" Conversion of Double to byte. ");
    System.out.println(" d  and b " + d  + " " + b);
    i=(int) d;
    System.out.println(" Conversion of double to integer. ");
    System.out.println(" d  and i " + d  + " " +i);
    }
}
```

៣. <u>សញ្ញាណនព្វន្ត(Arithmetic Operators)</u>

សញ្ញាណនព្វន្តដែលប្រើនៅក្នុង Java programming ក៏ដូចជាកនៅក្នុងកម្មវិធី C ឬ C++ ដែរ ខាងក្រោមជាសញ្ញា និងអត្ថន័យរបស់វា៖

សញ្ញា	អត្ថន័យ
+	បូក(Addition) ដើរតួម៉្យាងទៀតជាសញ្ញាភ្ជាប់ឃ្លា
-	ដក (Subtraction or unary minus)
*	គុណ (Multiplication)
/	ចែក (Division)
%	ចែករកសំណល់ (Modulus)
++	កំណើនមួយឯកតា (increment)
+=	កំណត់តំលៃនៃផលបូក (Addition assignment)
--	តំហាយមួយឯកតា (Decrement)

-=	កំណត់តំលៃនៃផលដក (Subtraction assignment)
*=	កំណត់តំលៃនៃផលគុណ (Multiplication assignment)
/=	កំណត់តំលៃនៃផលចែក (Division assignment)
%=	កំណត់តំលៃនៃផលចែកសំណល់ (Modulus assignment)

៣.១ <u>សញ្ញាណនព្វន្តសំខាន់ៗ (The Basic Arithmetic Operators)</u>

នៅក្នុងនេះមានសញ្ញាណនព្វន្តសំខាន់ៗចំនួន ៤ គឺសញ្ញា បូក ដក គុណ និង ចែក។

ឧទាហរណ៍៖

```
class  DemoBasArth{
        pubic static void main (String[] arg){
                int a = 1 ;
                int b = a + 3 ;
                int c = b * 5 ;
                int d = c / 4 ;
                int e = d – a ;
                System.out.println(" a = " + a);
                System.out.println(" b = " + b);
                System.out.println(" c = " + c);
                System.out.println(" d = " + d);
                System.out.println(" e = " + e);
                double a1 = 1 ;
                double b1 = a1 + 2 ;
                double c1 = b1 * 3 ;
                double d1 = c1 / 4 ;
                double e1 = d1 – a1 ;
                System.out.println(" a1 = " + a1);
                System.out.println(" b1 = " + b1);
                System.out.println(" c1 = " + c1);
                System.out.println(" d1 = " + d1);
                System.out.println(" e1 = " + e1);
        }
}
```

៣.២ <u>សញ្ញាណនព្វន្តចែករកសំណល់កំណត់តំលៃ កំណើន និងតំហាយ</u>

- ការចែករកសំណល់ គឺជាការចែករកសំណល់នៃផលចែកណាមួយ មិនមែនចែករកផលចែកនោះទេ។

```
class DemoModulus{
        public static void main (String[] arg){
                int a = 34 ;
                double b = 89.5 ;
                System.out.println ( " a mod 10 = " + a % 10);
                System.out.println ( " b mod 10 = " + b % 10);
        }
}
```

- ការប្រើសញ្ញាកំណត់តំលៃនៅក្នុង Java ក៏ដូចជានៅក្នុង C ឬ C++ ដែរ។ ទំរង់នៃការសរសេរមានដូចតទៅ ៖

  Variable = Variable Operator Expression

  ឬអាចសរសេរ Variable Operator = Expression

  ឧទាហរណ៍៖

  a = a + 2 ; សមមូល a += 2 ;
  a = a - 4 ; សមមូល a -= 4 ;
  a = a *3 ; សមមូល a *= 3 ;
  a = a / 5 ; សមមូល a /= 5 ;
  a = a % 2 ; សមមូល a %= 2 ;

  ……

- ការប្រើសញ្ញា កំណើន ឬតំហយ នៅក្នុង Java ក៏ដូចជានៅក្នុង C ឬ C++ ដែរ។ ទំរង់នៃការសរសេរមានដូចតទៅ ៖

  ឧទាហរណ៍៖

  x = x + 1 ; សមមូលនឹងការសរសេរ x++ ;
  x = x - 1 ; សមមូលនឹងការសរសេរ x-- ;

<u>ចំណាំ</u>៖ កំណើន ឬ តំហយ ប្រើបានតែកើន ឬក៏ ថយមួយឯកតាតែប៉ុណ្ណោះ។ បានន័យថាកើន ម្តង ១ ឬក៏ថយម្តង ១ ។

៣.៣ <u>សញ្ញាណនព្វន្តធៀប(Relational Operators)</u>

ដូចគ្នាទៅនឹងភាសា C ឬ C++ ដែរ ។ អត្តន័យ និងខ្លឹមសាររបស់និមិត្តសញ្ញាមានដូចខាងក្រោម៖

សញ្ញាណនព្វន្ត	អត្តន័យ
==	ស្មើគ្នានឹង
!=	មិនស្មើគ្នានឹង (ខុសពី)
>	ធំជាង
<	តូចជា
>=	ធំជាង ឬស្មើ
<=	តូចជាង ឬស្មើ

End

មេរៀនទី ៣

ផ្នែកឆ្លាត់លក្ខខណ្ឌ
Control Structure

Control Structure នៅក្នុង Java Programming ត្រូវបានគេចែកជាបីប្រភេទគឺ៖ Selection, Iteration និង Jump។

១.ប្រភេទ Selection

គឺជាឃ្លាមួយប្រភេទដែលធ្វើការជ្រើសរើសអនុវត្តការងារណាមួយក្នុងចំណោមការងារជាច្រើន។ នៅក្នុង Java Programming Control Structure ប្រភេទ Selection ចែកចេញជាពីរគឺ If statement និង Switch Case statement ។

១.១ If statement

នៅក្នុង Java Programming, If statement មានទម្រង់បីទម្រង់ផ្សេងគ្នា៖

a- if *(condition)*
    statement(s);

b- if *(condition)*
    statement*(s)*;
  else
    statement*(s)*;

c- if *(condition 1)*
    statement*(s)*;
  else if *(condition 2)*
    statement*(s);*
  else if *(condition 2)*
    statement*(s)*;
    ……
  else if *(condition n)*
    statement*(s)*;
  else
    statement*(s)*;

១.១.១ if *(condition)*

នៅក្នុង if នេះវាធ្វើការពិនិត្យលក្ខខណ្ឌ បើ **ពិត** នោះវាអនុវត្ត statement ដែលនៅបន្ទាប់ពីវា។ statement នោះអាចមានមួយ statement ឬក៏ច្រើន statements។ បើសិនជាមានច្រើន statements គឺយើងត្រូវសរសេរនៅក្នុងសញ្ញា {…} តែបើមានតែមួយ statement ទេ យើងមិនបាច់ដាក់នៅក្នុងសញ្ញា

{...} ទេ, តែបើដាក់ក៏មិនខុសដែរ។ ប៉ុន្តែប្រសិនបើ **មិនពិត** វិញ នោះវារំលង statement មួយដែលនៅបន្ទាប់ ឬ statementទាំងឡាយណាដែលនៅក្នុងសញ្ញា {...} ហើយទៅអនុវត្ត statement*(s)* ដែលនៅបន្តបន្ទាប់ ។

ឧទាហរណ៍ទី ១៖

```
class DemoIF{
        public static void  main(String[] agr){
                boolean b;
                if (b==true)
                        System.out.println("Repaired or Change New  ");
                System.out.println("This is the Test of If condition in Form 1 ");
        }
}
```

ឧទាហរណ៍ទី ២៖

```
class DemoIF{
        public static void  main(String[] agr){
                boolean b;
                if (b==true) {
                        System.out.println("Repaired ");
                        System.out.println("Or Change New  ");
                        }
                System.out.println("This is the Test of If condition in Form 1 ");
        }
}
```

១.១.២ if ...else statement

នៅក្នុង if នេះវាធ្វើការពិនិត្យលក្ខខណ្ឌដូចគ្នានឹង if ខាងលើដែរគឺ បើ **ពិត** នោះវាអនុវត្ត statement ដែលនៅបន្ទាប់ពីវា។ statement នោះអាចមានមួយ statement ឬក៏ច្រើន statements។ បើសិនជាមានច្រើន statements គឺយើងត្រូវសរសេរនៅក្នុងសញ្ញា {...} តែបើមានតែមួយ statement ទេ យើងមិនបាច់ដាក់នៅក្នុងសញ្ញា {...} ទេ, តែបើដាក់ក៏មិនខុសដែរ។ ប៉ុន្តែប្រសិនបើ **មិនពិត** វិញ វានឹងអនុវត្ត statement(s) ទាំងឡាយណាដែលស្ថិតនៅក្រោម else block ។

ឧទាហរណ៍ទី ១៖

```
class DemoIfElse{
        public static void  main(String[] agr){
                boolean b;
                if (b==true)
                        System.out.println("You can go now!  ");
                else
                        System.out.println("Wait! Wait! You must repair first! ");
        }
}
```

ឧទាហរណ៍ទី ២៖

```
class DemoIfElse{
        public static void  main(String[] agr){
                boolean b;
            if (b==true) {
                System.out.println("You can go now. ");
                System.out.println("Have a safe trip! ");
                }
            else {
                System.out.println("Wait! Wait! You must repair first! ");
                System.out.print("Otherwise");
                System.out.println("You will have an accident cause from it  ");
                }
        }
}
```

១.១.៣ if ...else if statement

ចំពោះទម្រង់ទី ៣ នេះវាមានជម្រើសច្រើនក្នុងការអនុវត្ត មានន័យថាទី១ វាត្រួតពិនិត្យលក្ខខណ្ឌ if សិន បើ**ពិត** វាអនុវត្ត statement *(s)* ទាំងឡាយណាដែលស្ថិតនៅក្រោម block *condition ទី ១។* តែបើ *condition* ទី១ **មិនពិតទេ** វានឹងត្រួតពិនិត្យ *condition ទី២* ទៀត ហើយបើ *លក្ខខណ្ឌទី២* **ពិត** វានឹងអនុវត្តនូវរាល់ statement*(s)* ទាំងឡាយណាដែលស្ថិតនៅក្រោម *conditionទី២* នោះ ផ្ទុយទៅវិញបើ *condition ទី២* **មិនពិត** វានឹងធ្វើការត្រួតពិនិត្យ លក្ខខណ្ឌបន្តបន្ទាប់ ដោយមានលំនាំដូចខាងលើរហូតដល់ ***condition ទី n*** ។ ជាចុងក្រោមបើ condition ពីទី១ រហូតដល់ទី n នៅតែ **<u>មិនពិត</u>** នោះវានឹងអនុវត្ត statement ចុងក្រោយគឺ else statement block ។

<u>ចំណាំ៖</u> ចំពោះ ទម្រង់ទី ៣ នេះ អាចមាន else ក៏បាន ឬមិនមានក៏បាន។ ហើយបើវាជួបលក្ខខណ្ឌណាមួយ **ពិត** ហើយ នោះវានឹងមិនត្រួតពិនិត្យលក្ខខណ្ឌបន្តបន្ទាប់ទៀតឡើយ ។

```
// Display the number of days in each month depend on year
class DemoIfElseIf{
        public static void main (String[] agr){
                boolean b; // to check the year mod 4 equal 0
                int year; // store year input
                int month; //store month input
                year=Integer.parseInt(agr[0]);
                month=Integer.parseInt(agr[1]);
                if ((year%4)==0)
                        b=true;
                else
                        b=false;
```

```
                if (month==1)
                        System.out.println(" This " + year + " January has 31 days");
                else if(month==2)
                        if (b==true)
                                System.out.println(" This " + year + " February has 29 days");
                        else
                                System.out.println(" This " + year + " February has 28 days");
                else if (month==3)
                        System.out.println(" This " + year + " March has 31 days");
                else if (month==4)
                        System.out.println(" This " + year + " April has 30 days");
                else if (month==5)
                        System.out.println(" This " + year + " May has 31 days");
                else if (month==6)
                        System.out.println(" This " + year + " June has 30 days");
                else if (month==7)
                        System.out.println(" This " + year + " July has 31 days");
                else if (month==8)
                        System.out.println(" This " + year + " August has 31 days");
                else if (month==9)
                        System.out.println(" This " + year + " September has 30 days");
                else if (month==10)
                        System.out.println(" This " + year + " October has 31 days");
                else if (month==11)
                        System.out.println(" This " + year + " November has 30 days");
                else if (month==12)
                        System.out.println(" This " + year + " December has 31 days");
                else
                        System.out.println(" Input invalid month (1-12) ");
        }
}
```

១.២. Switch case statement

Switch Case Statement ដូចគ្នាទៅនឹង if statement ទម្រង់ទី ៣ ដែរ។

ទម្រង់ទូទៅរបស់ Switch case ៖

```
switch (expression) {
        case value1 :
                statement(s);
                break;
```

```
        case value2 :
                statement(s);
                break;
        case value3 :
                statement(s);
                break;
        ……
        ……
        case value n :
                statement(s);
                break;
        default :
                statement(s);
}
```

ចំពោះ expression ត្រូវមានប្រភេទទិន្នន័យជា byte , short, int ឬក៏ char។ ចំណែក value ទាំងអស់នៅក្នុង case នីមួយៗត្រូវមានប្រភេទ ដូចនឹងប្រភេទទិន្នន័យរបស់ expression ដែរ ។ Values ទាំងអស់ត្រូវតែជាចំនួនថេរ មិនមែនជាអញ្ញាតឡើយ ហើយតម្លៃ value មិនត្រូវដូចគ្នាឡើយនៅក្នុង case នីមួយៗ។

ចំពោះ break វិញ គឺគេប្រើដើម្បីឲ្យវាបញ្ចប់ case នីមួយៗ ។ ប្រសិនបើគ្មាន break នៅក្នុង case នីមួយៗទេ នោះ Switch case statement គ្មានប្រយោជន៍អ្វីឡើយ ព្រោះវាអនុវត្តរាល់ statements ទាំងអស់ដែលនៅក្នុង Switch ដោយវាមិនបានអនុវត្តទៅតាមលក្ខខណ្ឌណាមួយឡើយ។

ឧទាហរណ៍៖

```
class DemoIfSwitchCase{
        public static void main (String[] agr){
                boolean b; // to check the year mod 4 equal 0
                int year; // store year input
                int month; //store month input
                year=Integer.parseInt(agr[0]);
                month=Integer.parseInt(agr[1]);
                if ((year%4)==0)
                        b=true;
                        else
                                b=false;
                switch (month){
                        case 1:
                                System.out.println(" This " + year + " January has 31 days");
                                break;
                case 2:
                        if (b==true)
```

```
                        System.out.println(" This " + year + " February has 29 days");
                    else
                        System.out.println(" This " + year + " February has 28 days");
                    break;
                case 3:
                    System.out.println(" This " + year + " March has 31 days");
                    break;
                case 4:
                    System.out.println(" This " + year + " April has 30 days");
                    break;
                case 5:
                    System.out.println(" This " + year + " May has 31 days");
                    break;
                case 6:
                    System.out.println(" This " + year + " June has 30 days");
                    break;
                case  7:
                    System.out.println(" This " + year + " July has 31 days");
                    break;
                case  8:
                    System.out.println(" This " + year + " August has 31 days");
                    break;
                case 9:
                    System.out.println(" This " + year + " September has 30 days");
                    break;
                case 10:
                    System.out.println(" This " + year + " October has 31 days");
                    break;
                case 11:
                    System.out.println(" This " + year + " November has 30 days");
                    break;
                case 12:
                    System.out.println(" This " + year + " December has 31 days");
                    break;
                default:
                    System.out.println(" Input invalid month (1-12) ");
            }
        }
```

២. ប្រភេទ Iteration

នៅក្នុង Java Programming ប្រភេទ Iteration ជាប្រភេទ control structure មួយប្រភេទដែលគេប្រើសម្រាប់ត្រួតពិនិត្យទៅលើដំណើរការដដែលៗ ។ ដែលក្នុងនោះរួមមាន for loop, while loop និង do-while loop ។

២.១ ការប្រើប្រាស់ for loop

យើងប្រើ for loop ដើម្បីអនុវត្តការងារដដែលៗក្នុងចន្លោះណាមួយ ដោយមានការបត់បែនទៅតាមអ្វីដែលយើងចង់បាន ។ for loop វាដំណើរការ statements ដែលនៅក្រោម block របស់វានៅពេល

ដែលលក្ខខណ្ឌវា **ពិត**។

ទម្រង់ទូទៅរបស់ for loop ៖

```
for (initialization ; condition ; iteration) {
        statement(s);
}
```

- Initialization : គឺជាកន្លែងដែលយើងផ្តល់តម្លៃចាប់ផ្តើម
- Condition : គឺជាលក្ខខណ្ឌដើម្បីត្រួតពិនិត្យថា **ពិត** ឬ **មិនពិត** ដើម្បីអនុវត្ត statement ដែលនៅក្រោម block របស់ for ។
- Iteration : គឺជាកំណើន ឬ តំហាយដែលធ្វើឲ្យ for loop បញ្ចប់ គឺវាធ្វើឲ្យលក្ខខណ្ឌ**មិនពិត**។

ឧទាហរណ៍៖ កម្មវិធីខាងក្រោមនេះបង្ហាញពីចំនួន **គូ** នៅចន្លោះណាមួយ តាមរយៈការបញ្ចូលពី keyboard នៅពេលដែលយើង **run** កម្មវិធី។

```
class DemoForLoop{
        public static void main(String[] agr){
                int n, m, i ;
                n=Integer.parseInt(agr[0]);
                m=Integer.parseInt(agr[1]);
                System.out.println ( "The Even number Between " + n + " and " + m   );
                for ( i=n ; i<m ; i++){
                        if (( i % 2 ) ==0)
                                System.out.print ( i + "    " );
                }
        }
}
```

២.១.១ <u>ការប្រកាសអញ្ញាតនៅក្នុងfor</u>

ការប្រកាសអញ្ញាតនៅក្នុង for គឺនៅពេលដែលយើងត្រូវការប្រើប្រាស់តែនៅក្នុង for block ហើយអញ្ញាតដែលប្រកាសក្នុង for នេះនៅពេលដែលចេញក្រៅ for មិនអាចប្រើប្រាស់បានទេ ។ ការប្រកាសនេះ យើងអាចប្រកាសបានតែនៅក្នុងផ្នែក Initialization តែមួយគត់ ។

ឧទាហរណ៍៖ កម្មវិធីខាងក្រោមនេះបង្ហាញពីចំនួន **សេស** នៅចន្លោះណាមួយ តាមរយៈការបញ្ចូលពី keyboard នៅពេលដែលយើង **run** កម្មវិធី។

```
class DemoForLoop{
        public static void main(String[] agr){
                int n, m ;
                n=Integer.parseInt(agr[0]);
                m=Integer.parseInt(agr[1]);
                System.out.println ( "The Even number Between " + n + " and " + m   );
```

```
                for ( int i=n ; i<m ; i++){
                    if (( i % 2 ) !=0)
                        System.out.print ( i + " " );
                }
            }
        }
```

២.១.២ ការប្រើសញ្ញា (,) នៅក្នុង for loop

ការប្រើសញ្ញា(,) នៅក្នុង for គឺនៅពេលដែលយើងចង់ប្រើអញ្ញាតពីរ ឬ ច្រើននៅក្នុងករណីដដែលៗ ដែលជំហាននៃ loop ដូចៗគ្នា ។ ការប្រើសញ្ញា (,) បានតែនៅក្នុងផ្នែក Initialization និង Iteration តែប៉ុណ្ណោះ ។

ឧទាហរណ៍៖

```
        for (int i=0, n=1 ; i<10 ; i++, n+=2){
            System.out.println(" i = " + i);
            System.out.println(" n = " +n);
        }
```

២.១.៣ ការប្រើទម្រង់ផ្សេងៗរបស់for

ឧទាហរណ៍ខាងក្រោមនេះ យើងអាចសរសេរតាមរបៀបណាមួយក៏បាន។

1.
```
int i, n;
 for ( i=0 ;  i<n ; i++ ) {
      System.out.println(" i = " + i );
 }
```
2.
```
int i, n;
 for ( i=0 ;  i<n ;  ) {
      System.out.println(" i = " + i );
     i+=1;
 }
```
3.
```
int i, n;
 i=0;
 for (  ;  i<n ;  ) {
     System.out.println(" i = " + i );
     i+=1;
     }
```
4.
```
int i, n;
 i=0;
 for ( ;  ;  ) {
```

```
        if (i<n)
                System.out.println(" i = " + i );
        else
                break;
        i +=1;
}
```

២.២ ការប្រើប្រាស់ while loop

ការប្រើ while ក៏មិនមានអ្វីខុសពី for ប៉ុន្មានដែរ ។ while វាធ្វើការត្រួតពិនិត្យលក្ខខណ្ឌជាមុនសិនមុននឹងការអនុវត្ត statements ដែលនៅក្រោម block របស់វា ។ while ដំណើរការតែនៅក្នុងករណីលក្ខខណ្ឌ **ពិត** តែប៉ុណ្ណោះ។

ទម្រង់ទូទៅរបស់ while

```
while (condition) {
        statement (s); // have iteration break,++,--
}
```

ឧទាហរណ៍៖ យើងចង់បង្ហាញលេខពី ១00 មក 0 ដោយថយម្តង ៣ ឯកតា។

```
class DemoWhile{
        public static void main(String[] agr){
                int n=100;
                while (n>0){
                        System.out.print( n + "    ");
                        n -= 3 ;
                }
        }
}
```

ឧទាហរណ៍៖ កម្មវិធីខាងក្រោមបង្ហាញពីការរាប់ចំនួន ដងនៃការបញ្ចូលពី keyboard រហូតដល់ពេលដែលយើងបញ្ចូលអក្សរ (n ឬ N)។

```
import java.util.Scanner;
class DemoWhile{
        static Scanner sc=new Scanner(System.in);
        public static void main(String[] agr){
            int num=2;
            String input;
            while (true){
                System.out.println(num + "  ");
```

```
                System.out.print(" count Countinue?(y or n)");
                input = sc.next();
                if (input.equalsIgnoreCase("N")) break;
                num+=1;
                }
            System.out.println(" Closed ! ");
        }
    }
```

២.៣ ការប្រើប្រាស់ do-while loop

ដំណើរការរបស់ do-while ក៏មិនខុសគ្នាពី while ដែរ គឺវាខុសគ្នាត្រង់ do-while យ៉ាងហោចណាស់ក៏អនុវត្តបានម្តងយ៉ាងតិច ទើបត្រួតពិនិត្យលក្ខខណ្ឌជាក្រោយ។ វាផ្ទុយពី while ត្រួតពិនិត្យលក្ខខណ្ឌមុនទើបអនុវត្តជាក្រោយ ។

```
class DemoDoWhile{
    public static void main(String[] agr){
        int n=100;
        do {
            System.out.print( n + "    ");
            n -= 3 ;
        }while (n<0);
    }
}
```

៣. ប្រភេទ Jump

នៅក្នុង Java Programming មាន Jump statement ចំនួន ៣ គឺ break, continue និង return។

៣.១ ការប្រើប្រាស់ break statement

break statement នៅក្នុង java programming គេអាចប្រើប្រាស់បាន **៣** ទម្រង់ផ្សេងៗគ្នា គឺ ប្រើសម្រាប់ចាកចេញពី switch case ,សម្រាប់ចាកចេញពី loop និងប្រើប្រាស់ដូច goto ។

៣.១.១ ការប្រើប្រាស់ break សម្រាប់ចាកចេញពី switch

យើងប្រើ break ដើម្បីចាកចេញពី switch case statement ដូចមាននៅក្នុងចំនុច **១.២** ក្នុងមេរៀននេះ ដែលនិយាយពីការប្រើប្រាស់ switch case statement ។

៣.១.២ ការប្រើប្រាស់ break សម្រាប់ចាកចេញពី loop

ការប្រើប្រាស់ break វាអាចបង្ខំឲ្យ loop មួយចាកចេញភ្លាមៗពី loop នោះដោយរំលងចោលនូវរាល់ statement*(s)* ដែលនៅសល់ក្នុង block របស់វា ។

ខាងក្រោមនេះជា ឧទាហរណ៍ដែលបញ្ជាក់ពីការប្រើប្រាស់ break សម្រាប់ចាកចេញពី loop។

```
// using break to exit from for loop
class DemoBreakForLoop{
        public static void main(String[] agr){
                int n = 100,i=0 ;
                for (int i = 0 ; i < n ; i++){
                        if ( i == 9 ) break ; // exit from the FOR loop, if i equal 9
                        System.out.print ( i + " " );   i++;
                }
                System.out.println();
                System.out.println("This statement is out of FOR LOOP! ");
        }
}

// using break to exit from while loop
class DemoBreakWhileLoop{
        public static void main(String[] agr){
                int n = 100 ;
                while ( i <n ){
                        if ( i == 9 ) break ; // exit from the WHILE loop, if i equal 9
                                System.out.print ( i + " " );
                }
                System.out.println();
                System.out.println("This statement is out of WHILE LOOP! ");
        }
}
```

៣.១.៣ ការប្រើប្រាស់ break ដូចនឹង goto

នៅក្នុង java program យើងអាចប្រើ break ជាមួយ Label ដើម្បីឲ្យវាមានលក្ខណៈដូចនឹង goto ។ ទម្រង់ទូទៅមានដូចខាងក្រោម៖

```
break Label ;
```

ឧទាហរណ៍៖

```
class DemoBreakGoto{
        public static void main(String[] agr){
                First: {
                        System.out.println( " Start First! ");
                        Second: {
                                System.out.println( " Start Second! ");
```

```
                    Third : {
                        System.out.println( " Start Third! ");
                        break Second;
                        System.out.println( " End Third! "); //not execute
                    }
                    System.out.println( " End Second! "); //not execute
                }
                System.out.println( " End First! "); //Executed
            }
        }
    }
```

៣.២ <u>ការប្រើប្រាស់ continue statement</u>

ការប្រើប្រាស់ continue មានលក្ខណៈដូចទៅនឹង goto Label ដែរ។ ប៉ុន្តែវាមានលក្ខណៈខុសគ្នាបន្តិចត្រង់ continue វារំលង statement*(s)* ដែលនៅសេសសល់ក្នុង loop ណាមួយទៅចុងបញ្ចប់នៃ loop ហើយវាបង្កើនមួយឯកតានៃ iteration របស់វា។

ឧទាហរណ៍ទី១៖

```
class DemoContinue1{
    public static void main(String[] agr){
        for ( int i = 0 ; i <10 ; i++){
            System.out.print( i + "  ");
            if ((i %2)==0) continue;
            System.out.println( " ");
        }
    }
}
```

ឧទាហរណ៍ទី២៖

```
class DemoContinue2{
    public static void main(String[] agr){
        outer: for ( int i = 0 ; i <10 ; i++){
            for (int j =0 ; j < 10 ; j++){
                if (j > i) {
                    System.out.println( );
                    continue outer;
```

```
                    }
                    System.out.print( " " + (i));
                }
            }
            System.out.println( );
        }
    }
```

៣.៣ ការប្រើប្រាស់ return statement

ឃ្លា return វាត្រូវបានប្រើសម្រាប់ឲ្យតម្លៃទៅ method មួយ។ នៅពេលណាក៏ដោយនៅក្នុង method មួយ ឃ្លា return អាចប្រើសម្រាប់ធ្វើឲ្យការប្រតិបត្តិត្រឡប់ទៅរកកន្លែងដែលហៅវាមកប្រើវិញ។

ឧទាហរណ៍៖

```
class  DemoReturn{
    public static void main (String[] agr){
        boolean b = true ;
        System.out.println(" Here before call return ");
        if (t) return;
        System.out.println(" After call RETURN "); // not Execute
    }
}
```

End

មេរៀនទី ៤

ការប្រើប្រាស់ *ARRAY*

Array

១. <u>និយមន័យ</u>

Array គឺជាបណ្តុំនៃ អញ្ញាតដែលមានប្រភេទទិន្នន័យដូចគ្នា ស្ថិតនៅក្រោមឈ្មោះតែមួយ តែវាញែកធាតុនីមួយៗដាច់ពីគ្នាដោយសារ Index ។

២. <u>Array មួយវិមាត្រ</u>

គឺជា array ដែលមានតែមួយជួរឈរ ពោលគឺមាន column តែមួយ មាន rows ច្រើន។

ទម្រង់ទូទៅនៃការប្រកាស array មួយវិមាត្រ ៖

```
Data-type  Array-name[ ] ;
```

ឬ

```
data-type [ ]  array-name ;
```

- data-type បញ្ជាក់ពីប្រភេទទិន្នន័យរបស់ array

ឧទាហរណ៍៖ យោងប្រកាស array មួយឈ្មោះថា day_in_month ដែលប្រើសម្រាប់រក្សាចំនួនថ្ងៃក្នុងខែនីមួយៗ យើងសរសេរដូចខាងក្រោម៖

```
int[ ] day_in_month ;
```

ការប្រកាសបែបនេះ វាមិនមានន័យថា យើងបានបង្កើត arrayមួយរួចហើយនោះទេ។ ដូច្នេះដើម្បីឲ្យវាបង្កើតជា array មួយយ៉ាងពិតប្រាកដ យើងត្រូវសរសេរដូចខាងក្រោម៖

```
int[ ] day_in_month ;
day_in_month = new int[12] ;
```

ឬ

```
int[ ] day_in_month = new int[12] ;
```

ឧទាហរណ៍៖

```
class DemoArray{
    public static void main(String[] agr){
        int day_in_month[ ] =new int[12];
        day_in_month[0]=31;
        day_in_month[1]=28 ;
        day_in_month[2]=31;
        day_in_month[3]=30;
        day_in_month[4]=31;
        day_in_month[5]=30;
        day_in_month[6]=31;
        day_in_month[7]=31;
        day_in_month[8]=30;
```

```
            day_in_month[9]=31;
            day_in_month[10]=30;
            day_in_month[11]=31;
            for (int i =0 ; i<12 ; i++)
                System.out.println ( " Month " + (i+1) + " has " + day_in_month[i] + "days ");
        }
    }
```

២.១ ការកំណត់តម្លៃដំបូងទៅឲ្យArray

ទម្រង់នៃការកំណត់តម្លៃដំបូងទៅឲ្យ array មួយវិមាត្រ៖

```
data-type array-name [ ] = {value1, value2, value3,……,valueN};
```

តាមរយៈឧទាហរណ៍ខាងលើយើងអាចសរសេរ៖

```
class DemoArray{
    public static void main(String[] agr){
        int day_in_month[ ] ={31,28, 31,30,31,30,31,31,30,31,30,31};
        for (int i =0 ; i<12 ; i++)
            System.out.println ( " Month " + (i+1) + " has " + day_in_month[i] + "days ");
    }
}
```

៣. Array ពីរវិមាត្រ

នៅក្នុង java programming យើងអាចប្រកាស array ពីរវិមាត្រដូចខាងក្រោម៖

```
data-type array-name[ ][ ] = new data-type[row][column] ;
```

ឧទាហរណ៍៖

```
class DemoArrayTwoD{
    public static void main (String [] agr){
        int myTwoArray[ ][ ] =new int [4][5];
        int i , j , k =1;
        for (i=0 ; i<4 ; i++)
            for (j=0 ; j<5 ; j++){
                myTwoArray[i][j] = (i + j) *k;
                k++;
            }
        for (i=0 ; i<4 ; i++)
            for (j=0 ; j<5 ; j++)
                System.ou.println ("myTwoArray[" +i+ "][" +j+ "] "+ myTwoArray[i][j]);
    }
}
```

ឧទាហរណ៍៖ បង្ហាញពីការបង្កើត array ពីរវិមាត្រ ដែលចំនួន column មិនស្មើគ្នា

```
class DemoArrayTwoD2{
        public static void main (String [] agr){
                int myTwoArray[ ][ ] =new int [4][ ];
                myTwoArray[0] =new int [1];
                myTwoArray[1] =new int [2];
                myTwoArray[2] =new int [3];
                myTwoArray[3] =new int [4];
                int i , j , k =0;
                for (i=0 ; i<4 ; i++)
                        for (j=0 ; j<i+1 ; j++){
                                myTwoArray[i][j] = k ;
                                k++;
                        }
                for (i=0 ; i<4 ; i++){
                     for (j=0 ; j<i+1 ; j++)
                          System.ou.print( myTwoArray[i][j] + " ");
                     System.out.println();
                }
        }
}
```

End

មេរៀនទី ៥

ការប្រើប្រាស់ Object នៅក្នុង Java

Object in Java

១. Classes

Classes គឺជា Template មួយសម្រាប់កំណត់ទម្រង់របស់ Object ។ នៅក្នុង classes អាចផ្ទុកទៅដោយ Methods (functions) , Variable , Initialization code ។ Classes មាន Members ពីរគឺ Methods និង Data (variable) ។ Data ឬ Variable នៅក្នុង class មួយគេហៅថា Instance variables ។ Methods និង Variables នៃ Class មួយត្រូវស្ថិតនៅក្នុងសញ្ញា {...} ។ យើងប្រកាស class មួយដោយប្រើ keyword ***class***។

ទម្រង់ទូទៅរបស់ Class ៖

```
class class_name {
        type instance_variable1 ;
        type instance_variable2 ;
        ……..…
        type instance_variablen ;
        type method_name1 (parameter-list){
                //body of method
        }
        type method_name2 (parameter-list){
                //body of method
        }
        ……..…
        type method_nameN (parameter-list){
                //body of method
        }
}
```

ឧទាហរណ៍៖ យើងបង្កើត class មួយឈ្មោះ Vehicle ដែលមាន Variables ចំនួន ៣ គឺ passengers, fuelcap និង mpg ដែលមានប្រភេទទិន្នន័យជា integer ។

```
class Vehicle {
        int passengers ; // number of passengers
        int fuelcap ;  // fuel capacity in gallons
        int mpg ;  //fuel consumption in mile per gallon
    }
```

ដើម្បីបង្កើត Object មួយចេញពី class Vehicleយើងត្រូវសរសេរដូចខាងក្រោម៖

```
Vehicle minibus;
minibus = new Vehicle();
```

ចំពោះ statement (Vehicle minibus) មិនមានន័យថាយើងបង្កើត Object Vehicle នោះទេ។ ផ្ទុយទៅវិញវាបង្កើត Variable មួយដែល refer ទៅ Object ប្រភេទជា Vehicle ។ ដើម្បីបង្កើត Object Vehicle យើងត្រូវប្រើ Keyword ***new*** ។ បន្ទាប់ពីយើងប្រើ Keyword ***new*** ទើបយើងអាចប្រើប្រាស់ Data និង Method របស់វាបាន។

ដើម្បីប្រើ data និង methods របស់ class មួយ គឺយើងប្រើប្រាស់តាមរយៈឈ្មោះរបស់ variable ដែលយើងប្រកាសចេញពី class នោះដោយភ្ជាប់ជាមួយសញ្ញា(.) និងឈ្មោះ data ឬ method ។

ឧទាហរណ៍៖ (Save ដាក់ឈ្មោះ DemoClass.java)

```
class Vehicle {
        int passengers ; // number of passengers
        int fuelcap ;  // fuel capacity in gallons
        int mpg ;  //fuel consumption in mile per gallon
    }

class DemoClass{
        public static void main(String[] agr){
                Vehicle minibus = new Vehicle();
                Vehicle minicar = new Vehicle();
                Int range1, range2;
                minibus.passengers = 12;
                minibus.fuelcap = 60 ;
                minibus.mpg = 10 ;
                minicar.passengers = 5;
                minicar.fuelcap = 45 ;
                minicar.mpg = 13 ;
                range1 = minibus.fuelcap * minibus.mpg ;
                range2 = minicar.fuelcap.minicar.mpg ;
                System.out.println("Minibus can carry " + minibus.passengers + " with the
                                range of " + range1 );
                System.out.println("Minicar can carry " + minicar.passengers + " with the
                                range of " + range2 );
        }
}
```

១.១ <u>អញ្ញាត Reference និងការកំណត់តម្លៃ</u>(Reference variable and Assignment)

យើងអាចកំណត់តម្លៃរបស់អញ្ញាតមួយដែលទទួលលក្ខណៈ object ទៅឲ្យអញ្ញាតមួយផ្សេងទៀត លក្ខណៈបែបនេះមានន័យថាអញ្ញាតដែលទទួល object នោះមានលក្ខណៈជាអញ្ញាត Reference ។

ឧទាហរណ៍៖

```
Vehicle car1=new Vehicle();
Vehicle car2=car1;
```

បើតាមយើងមើលទៅវាហាក់ដូចជា car1 និង car2 វាបញ្ជាក់ឲ្យ object ពីរផ្សេងគ្នា។ តែតាមពិតវាបញ្ជាក់ឲ្យ object តែមួយ។ ដូច្នេះការកំណត់តម្លៃទៅឲ្យ car1 ឬ car2គឺដូចគ្នា។

ឧទាហរណ៍៖

```
car1.passengers= 10;
```

បន្ទាប់មកយើងសរសេរដូចខាងក្រោម៖

```
System.out.println(car1.passengers);
System.out.println(car2.passengers);
```

ជាលទ្ធផលគឺវាបោះតម្លៃដូចគ្នាគឺ ១០ ។

២. <u>Method</u>

Method គឺជាធាតុមួយយ៉ាងសំខាន់នៅក្នុង java ព្រោះវាផ្តល់ឲ្យនូវអានុភាព និងភាពអាចផ្លាស់ប្តូរបានយ៉ាងច្រើន។ method មួយអាចមានឃ្លាមួយ ឬច្រើន។ method មួយត្រូវធ្វើការងារតែមួយមុខគត់ ហើយឈ្មោះរបស់វាប្រើសម្រាប់ហៅ method នោះមកប្រើវិញ។

ទម្រង់ទូទៅរបស់ Method ៖

```
return-type method-name(parameters-list){
    // body of methods
}
```

Return-type ៖ គឺវាជាបញ្ជាក់ប្រាប់ពីប្រភេទទិន្នន័យដែលទទួលបានពី method នោះ។

method-name ៖គឺជាឈ្មោះរបស់ method ដែលយើងប្រកាសើដើម្បីហៅវាមកប្រើប្រាស់។ ឈ្មោះរបស់វាគឺដាក់យ៉ាងណាឲ្យវាសមស្របទៅនឹងអ្វីដែលយើងចង់ធ្វើ ។

parameters-list ៖ គឺជាសៀរីនៃប្រភេទទិន្នន័យ និង Identifier ដែលវាញែកដាច់ពីគ្នាដោយសញ្ញា (,)។

ឧទាហរណ៍៖ យើងបន្ថែម ១ ទៅលើ class Vehicle គឺ Method ***range*** ប៉ុន្តែវាមាន return type ប្រភេទជា void ។

```
class Vehicle {
    int passengers ; // number of passengers
    int fuelcap ;  // fuel capacity in gallons
    int mpg ;  //fuel consumption in mile per gallon
```

```
        void range(){
            System.out.println("Range is " + fuelcap * mpg );
        }
    }
class DemoMethod{
        public static void main(String[] agr){
            Vehicle minibus = new Vehicle();
            Vehicle minicar = new Vehicle();
            Int range1, range2;
            minibus.passengers = 12;
            minibus.fuelcap = 60 ;
            minibus.mpg = 10 ;
            minicar.passengers = 5;
            minicar.fuelcap = 45 ;
            minicar.mpg = 13 ;
            System.out.println("Minibus can carry " + minibus.passengers );
            minibus.range();
            System.out.println("Minicar can carry " + minicar.passengers );
            minicar.range();
        }
}
```

នៅក្នុង method មួយយើងអាចផ្តល់តម្លៃឲ្យវា (method) បានតាមរយៈការប្រើប្រាស់ keyword ***return*** ។ ការប្រើប្រាស់ return មានពីររបៀបគឺ អាច return ដោយមាន value និង return ដោយគ្មាន value។

ចំពោះ method ដែលមាន return type ជា void យើងអាចបញ្ចប់ដំណើរការរបស់ method នោះភ្លាមៗដោយប្រើ keyword return ដោយគ្មាន value គឺ (return ;)។

ឧទាហរណ៍៖

```
void testVoidMethod(){
        for (int i=10 ; i>0 ; i--){
            if (i==3) return;
            System.out.print( i + " ");
        }
}
```

ចំពោះ method ទាំងឡាយណាដែលមាន return type ខុសពី void គឺយើងប្រើ return ដោយមាន value។ ឧទាហរណ៍យើងធ្វើការផ្លាស់ប្តូរ return type របស់ range ពី void ទៅជាប្រភេទ int វិញ។ code ខាងក្រោមបង្ហាញពីការប្រើប្រាស់របស់វា ។

```
class Vehicle {
        int passengers ; // number of passengers
        int fuelcap ;  // fuel capacity in gallons
        int mpg ;  //fuel consumption in mile per gallon
        int range(){
                return ( fuelcap * mpg );
        }
   }
class DemoReturnMethod{
        public static void main(String[] agr){
                Vehicle minibus = new Vehicle();
                Vehicle minicar = new Vehicle();
                Int range1, range2;
                minibus.passengers = 12;
                minibus.fuelcap = 60 ;
                minibus.mpg = 10 ;
                minicar.passengers = 5;
                minicar.fuelcap = 45 ;
                minicar.mpg = 13 ;
                System.out.println("Minibus can carry " + minibus.passengers + " with the
                                range of " + minibus.range() );
                System.out.println("Minicar can carry " + minicar.passengers + " with the
                                range of " + minicar.range() );
        }
}
```

២.១ ការប្រើ method ដែលមាន parameter

គេអាចបញ្ជូនតម្លៃមួយ ឬក៏ច្រើនទៅកាន់ method មួយនៅពេលដែលគេហៅវាមកប្រើប្រាស់ តម្លៃដែលយើងបញ្ជូនទៅនោះគេហៅថា argument ហើយអញ្ញាតដែលទទួលតម្លៃពី argument គេហៅថា parameter ។ parameter ត្រូវបានគេប្រកាសនៅពេលគេបង្កើត method ដោយដាក់នៅក្នុងសញ្ញា(...) បន្ទាប់ពីឈ្មោះរបស់ method ។

```
class MethodWithParamet{
        int addTwoNumber(int a , int b){
                return (a+b);
        }
        int minusTwoNumber(int a , int b){
                return (a-b);
        }
        int multTwoNumber(int a , int b){
                return (a*b);
        }
        int divTwoNumber(int a , int b){
                return (a/b);
        }
}
class DemoMethodParameter{
        public static void main (String[] agr){
        MethodWithParamet obj=new MethodWithParamet();
        int a , b ;
        a=Integer.parseInt(agr[0]);
        b=Integer.parseInt(agr[1]);
        System.out.println( a + " + " + b +" = " +obj.addTwoNumber(a,b));
        System.out.println( a + " - " + b +" = " +obj.minusTwoNumber(a,b));
        System.out.println( a + " * " + b +" = " +obj.multTwoNumber(a,b));
        System.out.println( a + " / " + b +" = " +obj.divTwoNumber(a,b));
        }
}
```

២.២ ការប្រើ *this* keyword

ការប្រើ keyword ***this*** វាមានសារៈសំខាន់ណាស់នៅក្នុងភាសា java ។ នៅពេលដែលនៅក្នុង class មួយដែលមាន variable ឈ្មោះដូចគ្នាច្រើន ប៉ុន្តែវាខុសគ្នាដោយសារ level (scope) ។

ឧទាហរណ៍៖

```
class Bird {
        int xPos, yPos;
                double fly ( int xPos, int yPos ) {
                        double distance = Math.sqrt( xPos*xPos + yPos*yPos );
```

```
                flap( distance );
                this.xPos = xPos;
                this.yPos = yPos;
                return distance;
            }
        }
```

នៅក្នុងឧទាហរណ៍នេះ ត្រង់ឃ្លា this.xPos និង this.yPos គឺវាសំដៅទៅលើ variable xPos និង yPos ដែលយើងប្រកាសនៅក្នុង class Bird មិនមែនជា parameter-list ដែលយើងប្រកាសនៅក្នុង method fly នោះទេ។ លក្ខណៈនេះហើយដែលយើងចាំបាច់ត្រូវប្រើ keyword ***this*** ដើម្បីញែកឲ្យដាច់ពីគ្នា។

២.៣ ការប្រើប្រាស់ Static Member

ជាធម្មតា member របស់ class មួយ ឬ របស់ object មួយ យើងអាចប្រើប្រាស់វាបាន (access) តាមរយៈឈ្មោះ object ដែលយើងប្រកាសវា ។ ប៉ុន្តែយើងក៏អាចប្រើប្រាស់វា (members) ដោយផ្ទាល់ដោយពុំចាំបាច់ឆ្លងកាត់ object ឡើយ គឺយើងប្រើប្រាស់ Static Member ។

ខាងក្រោមជាឧទាហរណ៍បង្ហាញពីការប្រើប្រាស់ static variable ដែលវាមាន shared៖

```
class VariableStatic{
    int x;
    static int y;
}
class DemoStatic{
    public static void main(String[] agr){
        VariableStatic obj1 = new VariableStatic();
        VariableStatic obj2 = new VariableStatic();
        obj1.x = 10 ;
        obj1.y = 12 ;
        obj2.x = 20 ;
        System.out.println(" X in obj1 and obj2 are different ");
        System.out.println(" obj1.x = " + obj1.x  + " obj2.x = " + obj2.x );
        System.out.println(" Y in obj1 and obj2 are the same ,because shared ");
        System.out.println(" obj1.y = " + obj1.y  + " obj2.y = " + obj2.y );
    }
}
```

ខាងក្រោមជាឧទាហរណ៍បង្ហាញពីការប្រើប្រាស់ static variable និង static method ៖

```
class VarMethStatic{
        static int x;
        static int y;
        static int add(){
                return x+y;
        }
}
class DemoStatic{
        public static void main(String[] agr){
                VarMethStatic.x = 10 ;
                VarMethStatic.y = 12 ;
                System.out.println(VarMethStatic.x + " + " + VarMethStatic.y + " = " +
                                VarMethStatic.add() ) ;
        }
}
```

<u>កំណត់ចំណាំ៖</u> ប្រការគួចងចាំចំពោះការប្រើប្រាស់ method មានលក្ខណៈ static

-វាអាចហៅប្រើបានតែ method ដែលមានលក្ខណៈ static ប៉ុណ្ណោះ

-វាអាចប្រើប្រាស់តែ data member(variable) ដែលមានលក្ខណៈ static ប៉ុណ្ណោះ

-វាមិនត្រូវមានការប្រើជាមួយ keyword ***this*** ឡើយ

ឧទាហរណ៍ class ខាងក្រោមនេះវាបង្ហាញពីការប្រើប្រាស់មិនត្រឹមត្រូវ

```
class ErrorStatic{
        int x ; // គឺជា instance variable ធម្មតា
        static int y ;  //ជា static variable
        static int add(){
                return x+y ;  //error won't compile
                // x មិនមែនជា static variable
        }
}
```

២.៤ <u>ការបញ្ជូនតម្លៃ Argument តាមរយៈ Value និង References</u>

នៅក្នុង java ក៏ដូចជានៅក្នុង programming ផ្សេងៗដែរការ passed argument មានពីរគឺ ដោយតម្លៃ និងដោយ reference ។ យើងធ្លាប់បានឃើញរួចមកហើយការ passes ដោយតម្លៃនៅក្នុង methods គឺ parameter-list របស់វាមានប្រភេទទិន្នន័យជា int , char, float...ជាដើម វាគឺជាប្រភេទ simple data

type។ ផ្ទុយទៅវិញការ passed ដោយ references គឺ parameter-list របស់វាមានប្រភេទទិន្នន័យជាប្រភេទ object ណាមួយ ជា array និងជា ប្រភេទទិន្នន័យ String ជាដើម។

ខាងក្រោមជាផ្នែកមួយនៃ code

```
.....
   int i = 0;
   SomeKindOfObject obj = new SomeKindOfObject( );
   myMethod( i, obj );
   ...
void myMethod(int j, SomeKindOfObject o) {
   ...
}
```

នៅពេលដែលយើងហៅ myMethod គឺវាមាន argument ពីរ ចំពោះ argument ទី១ គឺវា passed ដោយ value។នៅក្នុង code ខាងលើ i passed ដោយតម្លៃ ទោះបីជាយើងធ្វើការផ្លាស់ប្តូរតម្លៃ j នៅក្នុង myMethod យ៉ាងណាក៏ដោយ ក៏វាមិនមានការប្រែប្រួលតម្លៃ i ដែរ ។ ផ្ទុយទៅវិញចំពោះ obj ដែលផ្តល់ទៅឲ្យ parameter **o** នៅពេលដែលយើងធ្វើការផ្លាស់ប្តូរតម្លៃរបស់ o នោះវាធ្វើឲ្យមានការផ្លាស់ប្តូរតម្លៃរបស់ obj ផងដែរ។

២.៥ Methods Overloading

Methods Overloading គឺវាមានសមត្ថភាពអាចឲ្យយើងបង្កើត methods ដែលមានឈ្មោះដូចៗគ្នាជាច្រើននៅក្នុង Class តែមួយ។ ប៉ុន្តែវាមានការប្រើប្រាស់ខុសគ្នាទៅតាមអ្វីដែលយើងចង់បាន។

ច្បាប់នៃការ Overloading Methods ៖

- **ត្រូវតែមានឈ្មោះដូចគ្នា**
- **ខុសគ្នាដោយចំនួន parameter-list**
- **ខុសគ្នាដោយ parameter-type**
- **ប៉ុន្តែមិនមែនខុសគ្នាដោយសារreturn-type របស់ Methodsនោះទេ**

នៅក្នុង java ពេលវាហៅ method overloading មកប្រើវាប្រតិបត្តទៅលើ method ណាដែលមានប៉ារ៉ាម៉ែត្រត្រូវគ្នានឹង argument ដែលយើងហៅមកប្រើប្រាស់ (ទាំង data-type និង ចំនួន argument)។

ឧទាហរណ៍៖

```
class OverLoad{
int sum( int x , int y){
        return x+y ;
}
int sum( int x , int y, int z){
        return x+y+z ;
}
```

```
float sum( int x , float y){
        return x+y ;
}
float sum( float x , float y){
        return x+y ;
}
double sum( double x , float y){
        return x+y ;
}
……..…
}
class DemoOverload{
        public static void main(String[] agr){
        OverLoad obj = new OverLoad();
        System.out.println( obj.sum(10 , 20 ));
        System.out.println( obj.sum(10.0 , 20));
        System.out.println( obj.sum(10 , 20.5));
        System.out.println( obj.sum(0.5 , 20.5));
        }
}
```

២.៦ អំពី Recursive Method

                tm.put("Phan Thenghay",new Double(8765.43));
                tm.put("Lai Chansok",new Double(7654.32));
                tm.put("Srorn Seiha",new Double(9753.13));
                tm.put("You Hengadom",new Double(7531.31));
                //get a set of the entires
                Set set=tm.entrySet();
                //get an iterator
                Iterator itr = set.iterator();
                //display elements
                while(itr.hasNext()){
                        Map.Entry me=(Map.Entry)itr.next();
                        System.out.print(me.getKey() + ": ");
                        System.out.println(me.getValue());
                }
                System.out.println();
                //deposit 1111 into Srorn Seiha's account
                double balance =((Double)tm.get("Srorn Seiha")).doubleValue();
                tm.put("Srorn Seiha",new Double(balance + 1111));
                System.out.println("Srorn Seiha's new balance" + tm.get("Srorn Seiha"));
        }
}
```

លទ្ធផលទទួលបាន៖

```
Lai Chansok: 7654.32
You Hengadom: 7531.31
Lim Navuth: 5432.12
Choeun Net: 3456.43
Srorn Seiha: 9753.13
Lim Sothea: 9876.54
Phan Thenghay: 8765.43
Srorn Seiha's new balance10864.13
```

៩.៧ អំពី Arrays

Java 2 បានបន្ថែម class ថ្មីមួយទៀតទៅក្នុង java.util គឺ Arrays class វាផ្តល់នូវ methods ផ្សេងៗ ដែលមានសារៈសំខាន់នៅពេលយើងធ្វើការជាមួយ Arrays។ ទោះបីជា methods ទាំងនេះមិនមែនជាផ្នែកមួយនៃពពួក collection framework ក៏ដោយ ប៉ុន្តែវាជាស្ពានចម្លងចន្លោះរវាងពពួក collections និង array។

Methods ដែលកំណត់ដោយ Arrays class មាន៖

- Method asList() ឲ្យតម្លៃជា List ដែលត្រូវបានស្គាល់ដោយ Array ។ គេនិយាយម្យ៉ាងទៀតថា List និង Array បញ្ជាក់ឲ្យទីតាំងដូចគ្នា។ទម្រង់របស់វា៖

static List asList(Object[] array) // array គឺជាarray ផ្ទុកទិន្នន័យ

- Method binarySearch() ប្រើសម្រាប់តម្លៃដែលបានកំណត់ វាត្រូវបានប្រើជាមួយ array ដែលបានតំរៀបរួចជាស្រេច។ វានឹងផ្តល់នូវលេខ index នៃធាតុដែលយើង search ឃើញ។ តែបើsearch មិនឃើញវានឹងផ្តល់តម្លៃអវិជ្ជមាន។

ទម្រង់ទូទៅរបស់វា៖

static int binarySearch(byte[] array , byte value)
static int binarySearch(char[] array , char value)
static int binarySearch(double[] array , double value)
static int binarySearch(float[] array , float value)
static int binarySearch(int[] array , int value)
static int binarySearch(long[] array , long value)
static int binarySearch(short[] array , short value)
static int binarySearch(Object[] array , Object value)
static int binarySearch(Object[] array , Object value, Comparator c)

- Method equals() ប្រើសម្រាប់ប្រៀបធៀប array ពីរ បើសិនជា Array ទាំងពីរស្មើគ្នា វានឹងផ្តល់តម្លៃ true ផ្ទុយទៅវិញ វានឹងផ្តល់តម្លៃ false។

static boolean equals(boolean array1[] , boolean array2[])
static boolean equals(byte array1[] , byte array2[])
static boolean equals(char array1[] , char array2[])
static boolean equals(double array1[] , double array2[])
static boolean equals(float array1[] , float array2[])
static boolean equals(int array1[] , int array2[])
static boolean equals(long array1[] ,long array2[])
static boolean equals(short array1[] , short array2[])
static boolean equals(Object array1[] , Object array2[])

- Method fill() ប្រើសម្រាប់កំណត់តម្លៃមួយទៅឲ្យធាតុទាំងអស់នៅក្នុង array ។ យើងអាចនិយាយម្យ៉ាងទៀតថា វាបំពេញឲ្យ array នូវតម្លៃកំណត់មួយ ។ fill() មានពីរទម្រង់

ទម្រង់ទី១៖

```
static void fill(boolean[] array , boolean value)
static void fill(byte[] array , byte value)
static void fill(char[] array , char value)
static void fill(double[] array , double value)
static void fill(float[] array , float value)
static void fill(int[] array , int value)
static void fill(long[] array , long value)
static void fill(short[] array ,short value)
static void fill(Object[] array , Object value)
```

ទម្រង់ទី២៖

```
static void fill(boolean[] array ,int start, int end, boolean value)
static void fill(byte[] array , int start, int end, byte value)
static void fill(char[] array , int start, int end, char value)
static void fill(double[] array , int start, int end, double value)
static void fill(float[] array , int start, int end,float value)
static void fill(int[] array , int start, int end, int value)
static void fill(long[] array , int start, int end, long value)
static void fill(short[] array , int start, int end, short value)
static void fill(Object[] array , int start, int end, Object value)
```

methods ទាំងអស់នេះអាចប្រើជាមួយ Exception ប្រភេទ IllegalArgumentException នៅពេលដែល start ធំជាង end ឬក៏ ArrayIndexOutOfBoundsException កាលណា start ឬ end នៅក្រៅដែនកំណត់។

- Method sort() ត្រូវបានគេប្រើសម្រាប់តំរៀបទិន្នន័យក្នុង array តាមលំដាប់កើន។ វាមានពីរ ទម្រង់។

ទម្រង់ទី១៖ រៀបតាមលំដាប់ក្នុង array ទាំងមូល

```
static void sort(byte[] array)
static void sort(char[] array)
static void sort(double[] array)
static void sort(float[] array)
static void sort(int[] array)
static void sort(long[] array)
static void sort(short[] array)
static void sort(Object[] array)
```

static void sort(Object[] array, Comparator c)

ទម្រង់ទី២៖ រៀបតាមលំដាប់ក្នុង array ចន្លោះ index ពី start ដល់ end-1

methods ទាំងអស់នេះអាចប្រើជាមួយ Exception ប្រភេទ **static void sort(byte[] array, int start, int end)**

static void sort(char[] array, int start, int end)

static void sort(double[] array, int start, int end)

static void sort(float[] array, int start, int end)

static void sort(int[] array, int start, int end)

static void sort(long[] array, int start, int end)

static void sort(short[] array, int start, int end)

static void sort(Object[] array, int start, int end)

static void sort(Object[] array, int start, int end, Comparator c)

IllegalArgumentException នៅពេលដែល start ធំជាង end ឬក៏ ArrayIndexOutOfBounds-Exception កាលណា start ឬ end នៅក្រៅដែនកំណត់។

<u>ចំណាំ</u> ៖ គ្រប់ទម្រង់ទាំងអស់ ដែលមាន Comparator parameter អាចប្រើ ClassCastException កាលណាធាតុនៃ array ដែលត្រូវរៀបតាមលំដាប់នោះមិនអាចធ្វើការប្រៀបធៀបបាន។

ឧទាហរណ៍៖

```
import java.util.*;
class DemoArray{
        public static void main(String[] agr){
                int[] array=new int[10];
                for (int i=0 ; i<10 ; i++)
                        array[i]= -5*i ;
                //display  then sort and display again
                System.out.print("Original contents : ");
                display(array);
                Arrays.sort(array);
                System.out.print("Sorted : ");
                display(array);
                //fill and display
                Arrays.fill(array,2,6,-1);
                System.out.print("After fill() : ");
                display(array);
                //sort and diplay
                Arrays.sort(array);
                System.out.print("after sort again: ");
                display(array);
```

```
        //binary search for -15
        System.out.print("the value -15 in location : ");
        int index=Arrays.binarySearch(array,-15);
        System.out.println(index);

    }
    static void display(int[] array){
        for(int i=0;i<array.length;i++)
            System.out.print(array[i] + " ");
            System.out.println();
    }
}
```

លទ្ធផល៖

```
Original contents : 0 -5 -10 -15 -20 -25 -30 -35 -40 -45
Sorted : -45 -40 -35 -30 -25 -20 -15 -10 -5 0
After fill() : -45 -40 -1 -1 -1 -1 -15 -10 -5 0
after sort again: -45 -40 -15 -10 -5 -1 -1 -1 -1 0
the value -15 in location : 2
```

៥.៨ អំពី Vector

Vector វាមានលក្ខណៈដូចជា dynamic array ហើយវាស្រដៀងទៅនឹង ArrayList ដែរ ក៏ប៉ុន្តែវាមានភាពខុសគ្នាពីរគឺ Vector មានលក្ខណៈ synchronized ហើយនិងមាន methods ជាច្រើនដែលមិនមែនជាចំណែកនៃពួក collection។ ជាមួយ Java 2 នេះ Vector ទទួលលក្ខណៈពី AbstractList និងអនុវត្តតាម List interface ហេតុនេះវាមានលក្ខណៈត្រូវគ្នានឹង collections យ៉ាងពេញលេញ។

ទម្រង់ Constructors របស់ Vector៖

Vector( )

Vector(int size)

Vector(int size, int incr)

Vector(Collection c)

ចំពោះ vector កាលណាយើងមិនបានកំណត់តម្លៃតំបូងដូចក្នុងករណី constructor ទី១ វាឲ្យតម្លៃជា default គឺ ១០។ ចំពោះ incr ជាកំណើនទំហំរបស់ Vector រាល់ពេលដែល Vector នោះប្តូរទំហំ។ ហើយ constructor ទី៤ គឺបង្កើតនូវ vector មួយដែលមានធាតុនៃ collection វាត្រូវបានបន្ថែមឡើងដោយ Java 2 ។

គ្រប់ vectors ទាំងអស់ចាប់ផ្តើមឡើងដោយមានចំណុះតំបូង បន្ទាប់ពីចំណុះដំបូងនេះត្រូវបានអស់(ប្រើមកដល់ទំហំនេះ) ហើយនៅពេលដែលគេចង់ផ្ទុក Object នៅក្នុង vector នោះទៀត vector នឹងបង្កើតទីតាំងសម្រាប់ Object នោះ ដោយបូកទំហំសម្រាប់ object នោះដោយស្វ័យប្រវត្តិ។ តាមរយៈការបង្កើតទីតាំងលើសពីតម្រូវការ នោះ vector នឹងបន្ថយដោយស្វ័យប្រវត្តិដែរ។ បរិមាណនៃការបង្កើតទីតាំង

បន្ថែមត្រូវបានកំណត់នៅក្នុង (incr) នៅពេលយើងបង្កើត vector ។ បើមិនបញ្ជាក់ទេវានឹងកើនឡើងទ្វេតាមរយៈដំណើរបង្កើតទីតាំងនីមួយៗ។

Vector បានបង្កើត data members ដែលមានលក្ខណៈ protected ដូចខាងក្រោម៖

int capacityIncrement;

int elementCount;

Object elementData[];

តម្លៃកំណើនផ្ទុកក្នុង capacityIncrement, ចំនួនធាតុផ្ទុកក្នុង elementCount និងarray ដែលផ្ទុក vector ដាក់នៅក្នុង elementData។

Methods របស់ Vector ដែលអាចប្រើបានបន្ថែមទៅលើ methods ដែលមានក្នុងពពួក collections មានដូចខាងក្រោម៖

Methods Name	អធិប្បាយ
final void addElement(Object element)	បញ្ចូល element ថ្មីទៅក្នុង vector
final int capacity()	ប្រាប់ពីទំហំ(ចំណុះ) នៃ vector
Object clone()	ឲ្យតម្លៃស្ទួននៃ vector ដែលកំពុងប្រើ
final boolean contains(Object element)	ផ្តល់តម្លៃ true ប្រសិនបើ element នោះមាននៅក្នុងVector
final void copyInto(Object array[])	ចម្លងធាតុនៅក្នុង vector ទៅឲ្យ array
final Object elementAt(int index)	ផ្តល់ធាតុនៅត្រង់ index នោះ
final Enumeration elements()	ឲ្យតម្លៃជារបាប់នៃធាតុក្នុង vector
final ensureCapacity(int size)	កំណត់ចំណុះអប្បបរមានៃ vector ដោយ size
final Object firstElement()	ផ្តល់ធាតុទី១ នៅក្នុង vector
final int indexOf(Object element)	ផ្តល់តម្លៃ index របស់ element បើសិនជាមានក្នុង vector និងតម្លៃ -1 កាលណាគ្មាន element នៅក្នុង vector
final int indexOf(Object element,int start)	ផ្តល់តម្លៃ index នៅត្រង់ element ឬបន្ទាប់ start ផ្តល់តម្លៃ (-1) បើសិនជាមិនមាននៅក្នុង vector
final void insertElement(Object element, int index)	បញ្ចូល element ទៅក្នុង Vector នៅត្រង់ index
final boolean isEmpty()	ផ្តល់តម្លៃ true បើសិនជា vector គ្មានធាតុ
final Object lastElement()	ផ្តលតម្លៃ element ដែលនៅចុងក្រោយគេ
final int lastIndexOf(Object element)	ផ្តល់តម្លៃជា index នៅផ្នែកខាងចុងនៃ element បើសិនជា element មិនមាននៅក្នុង vector វាផ្តល់តម្លៃ -1
final int lastIndexOf(Object element, int start)	ផ្តល់តម្លៃជា index នៅផ្នែកខាងចុងនៃ element មុន start បើសិនជា element មិនមាននៅក្នុង vector វាផ្តល់តម្លៃ -1
final void removeAllElements()	លុបធាតុទាំងអស់ចេញពី vector
final boolean removeElement(Object	លុប element ចេញពី vector ហើយវាផ្តល់តម្លៃ true បើ

element)	សិនជាលុបបានជោគជ័យ
final void removeElementAt(int index)	លុប element នៅត្រង់ index
final void setElementAt(Object element, int index)	បញ្ចូល element ចូលក្នុង vector ត្រង់ index
final void setSize(int size)	ផ្តល់ទំហំ(ចំណុះ) size ទៅឲ្យ vector បើទំហំថ្មីតូចជាងទំហំចាស់ ពេលនោះបាត់បង់ធាតុ តែបើធំជាង ពេលនោះធាតុ null ត្រូវបានដាក់បញ្ចូល
final int size()	ផ្តល់តម្លៃជាចំនួនធាតុដែលកំពុងមាននៅក្នុង vector
String toString()	ឲ្យតម្លៃជា string ដែលសមមូលនឹង vector
final void trimToSize()	កំណត់ទំហំរបស់ vector ស្មើនឹងចំនួនធាតុដែលវាកំពុងផ្ទុក

ឧទាហរណ៍៖

```
import java.util.*;
class DemoVector{
        public static void main(String[] agr){
                //initial size of vector is 3 and increment by 2
                Vector v =new Vector(3,2);
                System.out.println("Initial size: " + v.size());
                System.out.println("Initial capacity: " + v.capacity());
                v.addElement(new Integer(1));
                v.addElement(new Integer(2));
                v.addElement(new Integer(3));
                v.addElement(new Integer(4));
                System.out.println("Capacity after added 4 integer Number :" + v.capacity());
                v.addElement(new Double(4.5));
                System.out.println("Current Capacity : " + v.capacity());
                v.addElement(new Double(6.08));
                v.addElement(new Integer(9));
                System.out.println("Current Capacity : " + v.capacity());
                v.addElement(new Float(9.4));
                v.addElement(new Integer(11));
                System.out.println("Current Capacity : " + v.capacity());
                System.out.println("First element : " +(Integer)v.firstElement() );
                System.out.println("Last element : " +(Integer)v.lastElement() );
                if (v.contains(new Integer(3)))
                System.out.println("Vector contain 3");
                //enumerate the elements in the vector
                Enumeration vEnum=v.elements();
```

```
                System.out.println("\nElements in vector:");
                while (vEnum.hasMoreElements())
                        System.out.print(vEnum.nextElement()+ " ");
                System.out.println();
        }
}
```

លទ្ធផលគឺ៖

```
Initial size: 0
Initial capacity: 3
Capacity after added 4 integer Number :5
Current Capacity : 5
Current Capacity : 7
Current Capacity : 9
First element : 1
Last element : 11
Vector contain 3

Elements in vector:
1 2 3 4 4.5 6.08 9 9.4 11
```

នៅក្នុង java 2 យើងអាចប្រើ iterator ជាមួយ Vector បានដែរ គេប្រើ iterator ជំនួសឲ្យការប្រើ enumeration ។

```
//use an iterator to display contents
Iterator itr=v.iterator();
System.out.println("\nElements in vector:");
while (itr.hasNext())
        System.out.print(itr.next()+ " ");
System.out.println();
```

៥. <u>អំពីការប្រើប្រាស់ Hashtable</u>

Hashtable class ស្ថិតនៅក្នុង java.util ហើយជា subclass មួយដែលទទួលលក្ខណៈពី abstract class មួយឈ្មោះ Dictionary ។ ទោះជាយ៉ាងណាក៏ដោយ Java 2 បានបង្កើតជាថ្មីនូវ Hashtable ដោយឲ្យវាអនុវត្តតាម Map interface ។ ដូច្នេះ Hashtable បានបញ្ចូលទៅក្នុងពពួក collections ។

Hashtable ផ្ទុកនូវតម្លៃ key/value ជាគូនៅក្នុងតារាង "hash"។ នៅពេលប្រើ Hashtable គេបញ្ជាក់នូវ object ដែលត្រូវប្រើជា key និងតម្លៃដែលគេចង់ភ្ជាប់ទៅនឹង key នោះ។ ពេលនោះ key ត្រូវធ្វើឲ្យទៅជា hash ហើយ hash code ដែលជាលទ្ធផលត្រូវបានប្រើជា index ដែលតម្លៃនោះផ្ទុកក្នុងតារាង។

Hash table អាចផ្ទុកតែ Objects ប៉ុណ្ណោះ ដែលសរសេរ Overriden លើ hashCode() method និង equals() method ហើយត្រូវបានកំណត់ដោយ object ។ hashCode() ត្រូវគណនា និងឲ្យតម្លៃជា hash

code សម្រាប់ object។ តាមពិត equals() ធ្វើការប្រៀបធៀប objects ពីរ ។ Java ផ្តល់នូវលក្ខណៈងាយស្រួលជាច្រើន ដោយវាមាន classes ដែលមានស្រាប់ ប្រើនូវ hashCode() ។ ឧទាហរណ៍ប្រភេទទិន្នន័យភាគច្រើនប្រើ String object ជា Key ។ String ប្រើទាំង hashCode() និង equals()។

ទម្រង់ Constructors របស់ Hashtable ៖

Hashtable()

Hashtable(int size)

Hashtable(int size, float fillRatio)

Hashtable(Map m)

ទម្រង់ទី១ ជា default constructor ។ទី២ បង្កើត hash table ដែលកំណត់ទំហំតម្លៃតំបូងគឺ size។ ទី៣ បង្កើតនូវ hash table ដូចនឹងទម្រង់ទី២ ដែរ តែវាមានចំនួនសមាមាត្រដែលត្រូវបំពេញ ។ ចំនួនសមាមាត្រត្រូវស្ថិតនៅចន្លោះ 0.0 និង 1.0 ហើយវាកំណត់នូវរបៀបដែល hash table ពេញមុននឹងត្រូវប្តូរទំហំ ។ ជាពិសេសនៅពេលចំនួនធាតុធំជាងចំណុះនៃ hash table គុណនឹងលេខសមាមាត្រដែលត្រូវបំពេញរបស់វា ពេលនោះ hash table នឹងត្រូវពង្រីក។ ប្រសិនបើយើងមិនបានបញ្ជាក់នូវចំនួនសមាមាត្រទេវានឹងប្រើ 0.75 ។ទម្រង់ចុងក្រោយបង្អស់ បង្កើតនូវ hash table មួយដែលកំណត់តម្លៃតំបូងដោយធាតុ Map m ទម្រង់នេះត្រូវបានបញ្ចូលដោយ java 2 ។

Methods ដែលអាចប្រើជាមួយ Hashtable ៖

ឈ្មោះ method	អធិប្បាយ
void clear()	Clear hash table
Object clone()	Clone Object ពីរដូចគ្នា
boolean contains(Object value)	ឲ្យតម្លៃ true បើសិនជា hash table មានផ្ទុក object value
boolean containsKey(Object key)	ឲ្យតម្លៃ true បើសិនជា hash table មានផ្ទុក object key នោះ
boolean containsValue(Object value)	ឲ្យតម្លៃ true បើសិនជា hash table មានផ្ទុក object value
Enumeration elements()	ឲ្យតម្លៃជាចំនួនរបាប់នៃតម្លៃដែលផ្ទុកក្នុង hash table
Object get(Object key)	ផ្តល់មកវិញនូវ Object ដែលត្រូវនឹង key បើគ្មានផ្តល់ null
boolean isEmpty()	ផ្តល់តម្លៃ true បើសិនជា hash table ទទេ
Enumeration keys()	ឲ្យតម្លៃជាចំនួនរបាប់នៃ key ដែលផ្ទុកក្នុង hash table
Object put(Object key, Object value)	បញ្ចូល key និង value ទៅក្នុង hash table
void rehash()	បង្កើនទំហំរបស់ hash table ហើយរៀបដាក់ជាថ្មីគ្រប់ keys ទាំងអស់របស់វាក្នុង hash table
Object remove(Object key)	លុបតម្លៃចេញពី hash table បើ key វាត្រូវគ្នា
int size()	ផ្តល់តម្លៃជាចំនួននៃការបញ្ចូលក្នុង hash table
String toString()	ឲ្យតម្លៃជា string ដែលសមមូលនឹង hash table

ឧទាហរណ៍៖

```
import java.util.*;
class DemoHashTable1{
    public static void main(String[] agr){
```

```
                Hashtable balance = new Hashtable();
                Enumeration names;
                String str;
                double bal;
                balance.put("Choeun Net",new Double(3456.43));
                balance.put("Lim Navuth",new Double(5432.12));
                balance.put("Lim Sothea",new Double(9876.54));
                balance.put("Phan Thenghay",new Double(8765.43));
                balance.put("Lai Chansok",new Double(7654.32));
                balance.put("Srorn Seiha",new Double(9753.13));
                balance.put("You Hengadom",new Double(7531.31));
                //show all balance in hash table
                names=balance.keys();
                while(names.hasMoreElements()){
                        str=(String) names.nextElement();
                        System.out.println(str + ": "+ balance.get(str));
                }
                System.out.println();
                //deposit 1111 into Srorn Seiha's account
                bal=((Double)balance.get("Srorn Seiha")).doubleValue();
                balance.put("Srorn Seiha",new Double(bal + 1111));
                System.out.println("Srorn Seiha's new balance" +
balance.get("Srorn Seiha"));
        }
}
```

លទ្ធផលគឺ៖

```
Lai Chansok: 7654.32
Lim Navuth: 5432.12
Srorn Seiha: 9753.13
Lim Sothea: 9876.54
You Hengadom: 7531.31
Phan Thenghay: 8765.43
Choeun Net: 3456.43

Srorn Seiha's new balance 10864.13
```

ចំណុចសំខាន់មួយគឺដូចទៅនឹង map class ដែរ hash table មិនអាចប្រើ iterators បានដោយផ្ទាល់ឡើយ ។ ហេតុនេះកម្មវិធីមុននេះប្រើ Enumeration ដើម្បីបង្ហាញតម្លៃនៃចំនួនទឹកប្រាក់។ ទោះជាយ៉ាងណាក៏ដោយ យើងក៏អាចប្រើ iterators បានដែរ។ ដើម្បីធ្វើដូច្នេះបាន យើងប្រើ method មួយក្នុងចំណោម methods របស់ពពួក collection ដែលកំណត់ដោយ Map ដូចជា entrySet() ឬ keySet()។

ឧទាហរណ៍៖

```
import java.util.*;
class DemoHashTable2{
	public static void main(String[] agr){
		Hashtable balance = new Hashtable();
		String str;
		double bal;
		balance.put("Choeun Net",new Double(3456.43));
		balance.put("Lim Navuth",new Double(5432.12));
		balance.put("Lim Sothea",new Double(9876.54));
		balance.put("Phan Thenghay",new Double(8765.43));
		balance.put("Lai Chansok",new Double(7654.32));
		balance.put("Srorn Seiha",new Double(9753.13));
		balance.put("You Hengadom",new Double(7531.31));
		//show all balance in hash table
		Set set=balance.keySet();
		//get iterator
		Iterator itr = set.iterator();
		while(itr.hasNext()){
			str=(String) itr.next();
			System.out.println(str + ": "+ balance.get(str));
		}
		System.out.println();
		//deposit 1111 into Srorn Seiha's account
		bal=((Double)balance.get("Srorn Seiha")).doubleValue();
		balance.put("Srorn Seiha",new Double(bal + 1111));
		System.out.println("Srorn Seiha's new balance" + balance.get("Srorn
Seiha"));
	}
}
```

លទ្ធផលគឺ៖

```
	Lai Chansok: 7654.32
	Lim Navuth: 5432.12
	Srorn Seiha: 9753.13
	Lim Sothea: 9876.54
	You Hengadom: 7531.31
	Phan Thenghay: 8765.43
	Choeun Net: 3456.43
	Srorn Seiha's new balance 10864.13
```

End

មេរៀនទី ១០

អំពីការប្រើប្រាស់ *Events*

១. អំពី Events

ការប្រើប្រាស់ event គឺដើម្បីឲ្យមានទំនាក់ទំនងជាមួយ applets និង components ផ្សេងៗទៀត។ Events ភាគច្រើនដែលគេប្រើនោះ គឺវាកើតឡើងដោយសារ mouse, keyboard និង controls ផ្សេងៗទៀត។ គេអាចប្រើ Events ទាំងអស់នៅក្នុង Java 2 តាមរយៈ Package មួយឈ្មោះ java.awt.event ។ យើងអាចប្រើ Event តាមលំនាំរបស់ Java 2 ដែលគេហៅថា delegation event model ជាជាងប្រើតាមលំនាំ Java version 1.0 ព្រោះតាមលំនាំ Java 2 នេះវាមានលក្ខណៈទូទៅ ច្បាស់លាស់ដែលអាចបង្កើត និងដំណើរការ Event បានយ៉ាងល្អ ពោលគឺ source បង្កើតនូវ event ហើយបញ្ជូន event នេះទៅកាន់ listeners មួយ ឬច្រើន។ listener រងចាំទទួល event ពេលទទួលបានហើយវាដំណើរការ event រួចបញ្ជូនលទ្ធផលត្រឡប់មកវិញ។

Java អាចដំណើរការ event ដោយមិនប្រើលំនាំ delegation event model បាន ដោយវាទទួលលក្ខណៈពី AWT component តែទោះជាយ៉ាងណាក៏វាពុំមានលក្ខណៈល្អប្រសើរដូចលំនាំ delegation event model ដែរ។

Event គឺជា object មួយដែលរៀបរាប់ពីបម្រែបម្រួលសភាពលក្ខណៈនៅក្នុង Source ។ វាកើតឡើងដោយសារអំពើរបស់ user ទៅលើសមាសធាតុនៅក្នុង graphical user interface ។ event វាអាចកើតឡើងពេលចុច button , បញ្ចូលតាម keyboard , ជ្រើសរើស items , ការចុចលើ mouse , timer ហួសកំណត់, counter ហួសតម្លៃ , software/ hardware មានបញ្ហាកើតឡើង ឬការប្រតិបត្តចប់សព្វគ្រប់ជាដើម។

២. អំពី Event Sources

Source គឺជា Object មួយបង្កើតនូវ event , វាអាចបង្កើតនូវ event មួយ ឬក៏ច្រើនបាន។ Source ត្រូវតែកត់ត្រានូវ listeners ដើម្បីឲ្យ listeners ទទួលសញ្ញាកំនត់ត្រាអំពីប្រភេទ event ដែលបានបញ្ជាក់។ ប្រភេទ event នីមួយៗ មាន methods កំណត់ត្រារបស់ខ្លួនរៀងៗខ្លួន។

ទម្រង់ទូទៅ៖

public void add*Type*Listener(*Type*Listener el)

ដែល *type* គឺជាឈ្មោះរបស់ event, el គឺ event listener ។

ឧទាហរណ៍ method ដែលកត់ត្រានូវ keyboard event listener គឺ addKeyListener(), method កត់ត្រានូវ mouse motion listener គឺ addMouseMotionListener()។ នៅពេល event មួយកើតឡើងនោះ គ្រប់ listeners ទាំងអស់ដែលបានកត់ត្រា ត្រូវកត់សំគាល់ និងទទួលនូវការចម្លងនៃ event object ដែលលក្ខណៈនេះត្រូវបានគេហៅថាmulticasting the event ។

Source ខ្លះអនុញ្ញាតឲ្យ listener តែមួយគត់សម្រាប់តក់ត្រា។ទម្រង់ទូទៅរបស់ method នេះគឺ៖

public void add*Type*Listener(*Type*Listener el) throws java.util.TooManyListenersException

កាលណា event **មួយកើតឡើង** listener **ដែលបានកត់ត្រា ត្រូវបានកត់សំគាល់ លក្ខណៈនេះ ត្រូវបានហៅថា** unicasting the event ។

Source **ត្រូវតែផ្តល់នូវវិធីមួយដែលអាចឲ្យ**listener **មួយលុបបំបាត់នូវកំណត់ត្រាចំពោះ**event **ណា មួយដែលបានបញ្ជាក់។ទម្រង់ទូទៅរបស់វា៖**

public void remove *Type*Listener(*Type*Listener el)

ឧទាហរណ៍ ដើម្បីលុបបំបាត់នូវkeyboard listener **គឺ** removeKeyListener()។

៣. <u>អំពី Event Listeners</u>

Listener **គឺជា** object **មួយដែលត្រូវបានកំណត់នៅពេល**event **មួយបានកើតឡើង ។ ទី១ វាត្រូវ តែកត់ត្រាទុកនូវ**source **មួយឬច្រើន ដើម្បីទទួលសញ្ញាកំណត់ត្រាប្រភេទ** events **ដែលបានបញ្ជាក់។ទី២ វាត្រូវប្រើ** methods **ដើម្បីទទួល និងដំណើរការសញ្ញាកំណត់ត្រាទាំងនេះ។**

Methods **ដែលទទួល** events **និងដំណើរការ** events **ត្រូវបានកំណត់នៅក្នុងសំនុំ** interface **ដែល ស្ថិតនៅក្នុង** java.awt.event ។

ឧទាហរណ៍៖ MouseMotionListener interface **មាន** methods **ពីរសម្រាប់ទទួលសញ្ញាកំណត់ត្រា នៅពេល** mouse **ត្រូវបានផ្លាស់ទី** (move) **ឬចុចសង្កត់ហើយរំកិល**(drag)។

៤. <u>អំពី Event Class</u>

Class **តាងឲ្យ** events **គឺជាស្នូលនៃការប្រើប្រាស់**event ។ **លំដាប់ថ្នាក់របស់** java event class **គឺ** event object **ដែលស្ថិតនៅក្នុង**java.util **វាជា** superclass **នៃ** event classes **ទាំងអស់។**

ទម្រង់ constructor **របស់វា៖**

EventObject(Object src) // src **គឺជា** object **ដែលបង្កើតនូវ**event **នេះ។**

EventObject **មាន** methods **ចំនួនពីរ គឺ** getSource() **ឲ្យតម្លៃជា** source **របស់** event **និង** toString() **ដែលឲ្យតម្លៃជា** String **សមមូលនឹង** event ។ **ដែលមានទម្រង់ទូទៅ៖**

Object getSourcce()

String toString()

Class **ឈ្មោះ** AWTEvent **មាននៅក្នុង** package java.awt **ហើយវាជា** subclass **នៃ** EventObject **ក៏ប៉ុន្តែវាជា** superclass **នៃ** event classes **ទាំងអស់ដែលមានមូលដ្ឋាននៅលើ** AWT (**ដោយផ្ទាល់ ឬដោយប្រយោល) ហើយប្រើនៅក្នុងលំនាំ** delegation event model ។ getID() method **របស់វាត្រូវបាន ប្រើសម្រាប់កំណត់ប្រភេទនៃ**event ។ **ទម្រង់របស់វាគឺ** int getID()។

តារាងខាងក្រោមនេះបង្ហាញនូវ event class **សំខាន់ៗ និងការអធិប្បាយដោយសង្ខេប នៅពេល ដែលវាត្រូវបានបង្កើតឡើង។**

<u>Event class</u>	<u>អធិប្បាយដោយសង្ខេប</u>
ActionEvent	កើតឡើងនៅពេលគេចុច button ឬ list item ត្រូវបានDouble-Click ឬ menu item ត្រូវបានជ្រើសរើស
AdjustmentEvent	កើតឡើងនៅពេលដែលយើងប្រើ scroll bar
ComponentEvent	កើតឡើងនៅពេល component មួយត្រូវបានបិទបាំង បង្ហាញឲ្យឃើញមកវិញ

	ផ្លាស់ទី ឬប្តូរទំហំ
ContainerEvent	កើតឡើងនៅពេល component មួយត្រូវបានបន្ថែមចូល ឬលុបចេញពី container
FocusEvent	កើតឡើងនៅពេល component មួយទទួល ឬបាត់បង់ keyboard focus
InputEvent	ជា abstract super class ចំពោះគ្រប់ events classes ទាំងអស់ដែលមានលក្ខណៈ input របស់ component
ItemEvent	កើតឡើងនៅពេល checkBox ឬ list item ត្រូវបានចុច ការជ្រើសយក item មួយនៃ Choice, ជ្រើសយក ឬលុបបំបាត់ការជ្រើសយក menu item ដែលមានលក្ខណៈ checkbox
KeyEvent	កើតឡើងនៅពេលមានការបញ្ចូល ឬបានទទួលពី keyboard
MouseEvent	កើតឡើងគ្រប់សកម្មភាពនីមួយៗរបស់ mouse
TextEvent	កើតឡើងនៅពេលតម្លៃរបស់ text area ឬ text field មានការប្រែប្រួល
WindowEvent	កើតឡើងនៅពេលដែល window មួយកំពុងមានសកម្មភាព ឬមិនមានសកម្មភាព ការបើក ការបិទ ការបង្រួម ការពង្រីក...

៤.១ អំពី ActionEvent

ActionEvent class **មានបួនតម្លៃថេរ ដែលជាចំនួនគត់ត្រូវបានប្រើសម្រាប់សំគាល់សភាពប្រែប្រួលណាមួយដែលទាក់ទងទៅនឹង** action event : ALT_MASK, CTRL_MASK, META_MASK **និង** SHIFT_MASK **។ លើសពីនេះវាក៏មានតម្លៃថេរមួយគឺ** ACTION_PERFORMED **ដែលត្រូវបានប្រើសម្រាប់សំគាល់** action event **។**

ActionEvent class **មាន**constructor **ចំនួនពីរ៖**

ActionEvent (Object src, int type, String cmd)

ActionEvent (Object src, int type, String cmd, int modifiers)

ក្នុងនេះ scr **ជា** reference **សម្រាប់** object **ដែលបានបង្កើត** event **នេះ** , type **បញ្ជាក់ពីប្រភេទ** event, cmd **ជាអក្សរនៃពាក្យបញ្ជារបស់វានិង** modifiers **ប្រាប់នូវ** key **ណាមួយបានចុច ឬផ្លាស់ប្តូរ** (ALT, CTRL, META, SHIFT)**។**

គេអាចទទួលបានឈ្មោះពាក្យបញ្ជាសម្រាប់ប្រើជាមួយ ActionEvent Object **តាមរយៈ** getAction-Command() **ដែលមានទម្រង់ដូចខាងក្រោម៖**

String getActionCommand()

getMidifiers() method **នឹងឲ្យតម្លៃមួយសម្រាប់ប្រាប់នូវ**keys **ណាដែលមានសភាពប្រែប្រួល**(ALT, CTRL, META, SHIFT) **ត្រូវបានចុច នៅពេល** event **បានកើតឡើង ។**

int getModifiers()

៤.២ អំពី AdjustmentEvent

មានប្រភេទចំនួន ៥ adjustment event **។** AdjustmentEvent **មានចំនួនថេរជាចំនួនគត់សម្រាប់សំគាល់** events **ដូចបង្ហាញក្នុងតារាងខាងក្រោម៖**

BLOCK_DECREMENT	ពេលយើងចុចខាងក្នុង scroll bar ដើម្បីបន្ថយតម្លៃ
BLOCK_INCREMENT	ពេលយើងចុចខាងក្នុង scroll bar ដើម្បីបង្កើនតម្លៃ
TRACK	នៅពេលយើង Slider ត្រូវចុចបង្ហូស
UNIT_DECREMENT	ចំនុចខាងចុងនៃ Scroll bar ត្រូវបានចុចបន្ថយតម្លៃរបស់វា
UNIT_INCREMENT	ចំនុចខាងចុងនៃ Scroll bar ត្រូវបានចុចបង្កើនតម្លៃរបស់វា

លើសពីនេះទៅទៀតវាមានចំនួនថេរមួយជាចំនួនគត់ គឺ ADJUSTMENT_VALUE_CHANGED **ដែលបង្ហាញថាការប្រែប្រួលបានកើតឡើង។**

Constructor **របស់វា៖**

AdjustmentEvent(Adjustable, src, int id, int type, int data)

-src **គឺជា** reference **នៃ** Object **ដែលបានបង្កើត** event

-id **សមមូលនឹង** ADJUSTMENT_VALUE_CHANGED

-**ប្រភេទនៃ** event **ត្រូវបានបញ្ជាក់តាមរយៈ**type

-**ទិន្នន័យដែលមានទំនាក់ទំនងជាមួយគ្នាគឺ**data

getAdjustable() **ឲ្យតម្លៃជា** object **ដែលបានបង្កើតនូវ**event **។ ទម្រង់របស់វាគឺ៖**

Adjustable getAdjustable()

ប្រភេទនៃ Adjustment event **អាចទទួលបានតាមរយៈ:** Adjustable getAdjustmentType() **។ វាឲ្យតម្លៃជាចំនួនថេរដែលមាននៅក្នុង** AdjustmentEvent **។ ទម្រង់របស់វា៖**

getAdjustmentType()

បរិមាណនៃតម្រូវការអាចទទួលបានតាមរយៈ:getValue() **។ ទម្រង់របស់វា៖**

getValue()

៤.៣ <u>អំពី ComponentEvent</u>

ComponentEvent **កើតឡើងនៅពេលដែល ទំហំ ទីតាំង ឬភាពមើលឃើញរបស់** component **មួយមានការផ្លាស់ប្តូរ ។ វាមានប្រភេទ** component event **ចំនួន ៤ ដែលជាចំនួនថេរសម្រាប់សំគាល់** events **នីមួយៗដូចខាងក្រោម៖**

COMPONENT_HIDDEN	នៅពេលដែល component មួយត្រូវបានបិតបាំង
COMPONENT_MOVED	នៅពេលដែល component មួយត្រូវបានផ្លាស់ទី
COMPONENT_RESIZED	នៅពេលដែល component មួយត្រូវបានប្តូរទំហំ
COMPONENT_SHOWN	នៅពេលដែល component មួយត្រូវបានបង្ហាញឲ្យឃើញវិញ

៤.៤ <u>អំពី ContainerEvent</u>

ContainerEvent **កើតឡើងនៅពេល** component **មួយត្រូវបានបន្ថែមចូលឬលុបចេញពី** container **។** ContainerEvent **មានចំនួនថេរជាចំនួនគត់ដែលអាចប្រើសម្រាប់សំគាល់**Container events **ដូចជា៖** COMPONENT_ADDED **និង** COMPONENT_REMOVED **។**

ContainerEvent **គឺជា** subclass **នៃ** ComponentEvent **មាន** Constructor **ដូចខាងក្រោម៖**

ContainerEvent(Component src , int type, Component comp)

-src ជា reference សម្រាប់ container ដែលបានបង្កើត event នេះ

-type បញ្ជាក់ពីប្រភេទ event

-comp គឺជា component មួយត្រូវបានបន្ថែមចូលឬលុបចេញពី container ។

យើងអាចទទួលបាន reference **សម្រាប់** container **ដែលបង្កើតនូវ** event **នេះដោយប្រើ** getContainer() method **ដែលមានទម្រង់ដូចខាងក្រោម៖**

Container getContainner()

getChild)() method **ឲ្យតម្លៃជា** reference **ចំពោះ** component **ដែលបានបន្ថែមចូលឬលុបចេញ។**

ទម្រង់ទូទៅ៖

Component getChild()

៤.៥ <u>អំពី FocusEvent</u>

FocusEvent **កើតឡើងនៅពេល** component **មួយទទួល ឬបាត់បង់** keyboard focus ។ events **ទាំងនោះត្រូវបានសំគាល់ដោយចំនួនថេរជាចំនួនគត់គឺ**FOCUS_GAINED **និង** FOCUS_LOST ។

Constructor **របស់** FocusEvent **៖**

FocusEvent(Component src, int type)

FocusEvent(Component src, int type, boolean *temporaryFlag*)

-src **និង** type **ដូចខាងលើ ចំពោះ** temporary **ត្រូវកំណត់តម្លៃ** true **បើសិន** focus event **ស្ថិតក្នុងសភាព** temporary ។ **ផ្ទុយទៅវិញត្រូវកំណត់តម្លៃ** false ។ **បានន័យថា** focus event **ដែលមានលក្ខណៈ** temporary **កើតឡើងដោយសារលទ្ធផលនៃការប្រតិបត្តលើ** user interface **ផ្សេងទៀត។ ឧទាហរណ៍ឧបមាថា** focus **កំពុងស្ថិតក្នុង** text field **ហើយប្រសិនបើជាអ្នកប្រើបានផ្លាស់ទី** mouse **ដើម្បីតម្រូវ** scrollbar **នោះ** focus **ត្រូវបាត់បង់សភាព** temporary ។

isTemporary() method **ប្រាប់ឲ្យដឹងនូវភាពបម្រែបម្រួល** focus **នេះកំពុងស្ថិតនៅក្នុងលក្ខណៈ** temporary **ដែរ ឬទេ។ ទម្រង់របស់វា៖**

boolean isTemporary()

វាឲ្យតម្លៃ true **កាលណាសភាពប្រែប្រួលកំពុងស្ថិតក្នុងលក្ខណៈ**temporary**។**

៤.៦ <u>អំពី InputEvent</u>

InputEvent **គឺជា** abstract class **ដែលជា** subclass **នៃ** ComponentEvent **និងជា** superclass **ចំពោះ** input event **របស់** component**។** subclass **របស់វាមាន** KeyEvent **និង** MouseEvent**។** InputEvent class **មាន ៨ ចំនួនថេរជាចំនួនគត់ ដែលប្រើដើម្បីទទួលព័ត៌មានអំពី** modifier **ណាមួយដែលមានទំនាក់ទំនងជាមួយនឹង** event ។ **ចំនួនថេរទាំងនោះមាន៖**

ALT_MASK	ALT_GRAPH_MASK	META_MASK
BUTTON1_MASK	BUTTON2_MASK	BUTTON3_MASK
SHIFT_MASK	CTRL_MASK	

យើងមាន methods **ប្រើសម្រាប់ផ្ទៀងផ្ទាត់ ប្រសិនបើ** modifiers **ទាំងនោះត្រូវបានចុចក្នុងខណៈដែល** event **នេះ ដូចខាងក្រោម៖**

boolean isAltDown()

boolean isAltGraphDown()

boolean isControlDown()

boolean isMetaDown()

boolean isShiftDown()

getModifiers() ឲ្យតម្លៃមួយដែលមានគ្រប់ modifier flags សម្រាប់ event នេះ។ វាមានទម្រង់ដូចខាងក្រោម៖

int getModifiers()

៤.៧ អំពី ItemEvent

ItemEvent កើតឡើងនៅពេល checkBox ឬ list item ត្រូវបានចុច ការជ្រើសយក item មួយនៃ Choice ជ្រើសយក ឬលុបបំបាត់ការជ្រើសយក menu item ដែលមានលក្ខណៈ checkBox ។ វាមាន item events ពីរប្រភេទដែលសំគាល់ដោយចំនួនថេរ និងចំនួនថេរមួយដែលផ្តល់សញ្ញាប្រែប្រួលនៃសភាពលក្ខណៈ គឺ៖

- DESELECTED និង SELECTED
- ITEM_STATE_CHANGED

Constructor របស់ ItemEvent ៖

ItemEvent(ItemSelectable src, int type, Object entry, int state)

- src ជា reference សម្រាប់ component ដែលបានបង្កើត event ជាក់ស្តែងវាអាចជាធាតុរបស់ Choice ឬ list ។
- type បញ្ជាក់ឲ្យប្រភេទ Event
- item ដែលបង្កើតនូវ item event ត្រូវបានបញ្ជូនតាមរយៈ entry
- state បញ្ជាក់ប្រាប់ពីសភាពលក្ខណៈកំពុងមាននៅលើitem

យើងអាចប្រើ getItem() ដើម្បីទទួលបាននូវ reference ចំពោះ item ដែលបង្កើតឡើងនូវ event។

ទម្រង់របស់វា៖

Object getItem()

getItemSelectable() សម្រាប់ទទួលយកនូវ reference ចំពោះ ItemSelectable object ដែលបានកើតមាន event ។

ទម្រង់របស់វា៖

ItemSelectable getItemSelectable()

getStateChange() សម្រាប់ឲ្យតម្លៃជាសភាពប្រែប្រួលSELECTED ឬ DESELECTED ។

ទម្រង់របស់វា៖

int getStateChange()

៤.៨ អំពី KeyEvent

កើតឡើងនៅពេលមានការបញ្ចូល ឬបានទទួលពី keyboard ។ វាមានចំនួនថេរ ៣ សម្រាប់

សំគាល់ប្រភេទ event **របស់វាគឺ** KEY_PRESSED, KEY_RELEASED **និង** KEY_TYPED **។ វាមានចំនួនថេរមួយចំនួនទៀត ដែលកំណត់ដោយ** KeyEvent **មានដូចជា៖** VK_0 **ដល់** VK_9, VK_A **ដល់** VK_Z, VK_a **ដល់** VK_z...**ដែលមាន** ASCII **ត្រូវគ្នានឹងលេខ និងអក្សរ។ ហើយក៏មានចំនួនថេរមួយចំនួនទៀតដែរ ដូចជា៖**

VK_ENTER	VK_ESCAPE	VK_CANCEL	VK_UP
VK_DOWN	VK_LEFT	VK_RIGHT	VK_PAGE_DOWN
VK_PAGE_UP	VK_SHIFT	VK_ALT	VK_CONTROL

ដែល VK **បញ្ជាក់ឲ្យ** virtual key code **ហើយមានលក្ខណៈមិនអាស្រ័យនឹង** modifiers **ណាមួយឡើយ ដូចជា** control, shift **ឬ** alt **។**

វាមាន Constructor **ដូចខាងក្រោម៖**

KeyEvent(Component src, int type, long when, int modifiers, int code)

KeyEvent(Component src, int type, long when, int modifiers, int code, char ch)

- src **ជា** reference **សម្រាប់** component **ដែលបានបង្កើត** event

-type **បញ្ជាក់ពីប្រភេទនៃ** event

-when **បញ្ជាក់ពីពេលវេលាដែល**key **បានចុចបញ្ចូន**

-modifiers **ប្រាប់នូវ** modifiers **ណាដែលបានចុចនៅពេល** key event **នេះកើតឡើង**

-code **ជាកន្លែងដែលត្រូវបញ្ចូន**virtual key code

-ch **ជាកន្លែងដែល តួអក្សរដែលសមមូលនឹងត្រូវបញ្ចូន ប្រសិនបើពុំមានតួអក្សរត្រឹមត្រូវទេ ពេលនោះ** ch **មានតម្លៃជា** CHAR_UNDEFINED **ចំពោះ** KEY_TYPED events **វិញ** code **នឹងមានតម្លៃជា** VK_UNDEFINED **។**

KeyEvent **មាន** methods **ជាច្រើន ប៉ុន្តែ** methods **ដែលយើងប្រើញឹកញាប់ជាគេគឺ**getKeyChar() **និង** getKeyCode()**។**

Constructor **របស់** methods **ទាំងពីរគឺ៖**

char getKeyChar()

int getKeyCode()

បើវាប្រើតួអក្សរមិនត្រឹមត្រូវនោះ getKeyChar() **ឲ្យតម្លៃជា** CHAR_UNDEFINED **។ កាលណា** KEY_TYPED event **កើតឡើង ពេលនោះ** getKeyCode() **ឲ្យតម្លៃជា** VK_UNDEFINED **។**

៤.៩ <u>អំពី MouseEvent</u>

ក្នុងនោះវាមានចំនួនថេរដែលប្រើប្រាស់នៅក្នុង MouseEvent **ដូចខាងក្រោម៖**

MOUSE_CLICKED	កើតឡើងនៅពេលដែលយើង click
MOUSE_DRAGGED	កើតឡើងនៅពេលដែលយើងចុចអូស mouse
MOUSE_ENTERED	កើតឡើងនៅពេលដែល mouse pointer អូសកាត់ component
MOUSE_EXITED	កើតឡើងនៅពេល mouse pointer រំកិលផុតពី Component
MOUSE_MOVED	កើតឡើងនៅពេលដែលយើងផ្លាស់ទី mouse pointer
MOUSE_PRESSED	កើតឡើងនៅពេលដែល mouse ត្រូវបានយើងចុចជាប់
MOUSE_RELEASED	កើតឡើងនៅពេលដែលយើងព្រលែង mouse ពីការចុច

Constructor របស់ MouseEvent ៖

MouseEvent(Component src, int type, long when, int modifiers, int x, int y,int clicks, boolean triggersPopup)

-src ជា reference សម្រាប់ component ដែលបានបង្កើត event

-type បញ្ជាក់ពីប្រភេទនៃ event

-when បញ្ជាក់ពីពេលវេលាដែល mouse បានចុចបញ្ជូន

-modifiers ប្រាប់នូវ modifiers ណាដែលបានចុច នៅពេល mouse event នេះកើតឡើង

- x និង y ប្រាប់ពីកូអរដោនេ នៅពេលដែល mouse event កើតឡើងនៅត្រង់ណា

-clicks ប្រាប់ពីចំនួនដងនៃការclick

-triggersPopup ប្រាប់ឲ្យដឹងថា បើសិនជា event នេះនាំឲ្យមាន popup-menu លេចឡើងលើ platform មានតម្លៃ true ផ្ទុយទៅវិញត្រូវដាក់តម្លៃfalse ។

Methods ដែលប្រើញឹកញាប់ជាងគេគឺgetX() និង getY()។ទម្រង់របស់វា៖

```
int getX()
int getY()
```

យើងអាចប្រើ getPoint() ដើម្បីទទួលយកបាននូវកូអរដោនេរបស់mouse បាន។

```
Point getPoint()
```

យើងប្រើ translatePoint() ដើម្បីបំលាស់ប្តូរទីតាំងនៃevent ។

```
void translatePoint(int x, int y)
```

យើងប្រើ getClickCount() ដើម្បីទទួលបាននូវចំនួនដងនៃការclick

```
int getClickCount()
```

យើងប្រើ isPopupTrigger() ដើម្បីផ្ទៀងផ្ទាត់ថាតើ event នេះមាន popup menu ដែរ ឬទេ។

```
boolean isPopupTrigger()
```

៥.១០ អំពី TextEvent

TextEvent បង្កើតឡើងដោយ text field និង text area កាលណាតួអក្សរត្រូវបានបញ្ចូលដោយ user ឬដោយកម្មវិធី។ ចំនួនថេរដែលប្រើជាមួយTextEvent គឺ TEXT_VALUE_CHANGED ។

ទម្រង់ Constructor របស់ TextEvent ៖

```
TextEvent(Object src, int type)
```

៥.១១ អំពី WindowEvent

WindowEvent មានចំនួនថេរដែលប្រើសម្រាប់សំគាល់event នេះដូចខាងក្រោម៖

WINDOW_ACTIVATED	កើតឡើងនៅពេលដែល window កំពុងមានសកម្មភាពលើវា
WINDOW_CLOSED	កើតឡើងនៅពេលដែល window ត្រូវបានបិទ
WINDOW_CLOSING	កើតឡើងនៅពេលដែល window កំពុងត្រូវបានចុចបិទ
WINDOW_DEACTIVATED	កើតឡើងនៅពេលដែល window ពុំមានសកម្មភាពលើវា

WINDOW_DEICONIFIED	កើតឡើងនៅពេលដែល window ត្រូវបាន maximize វិញ
WINDOW_ICONIFIED	កើតឡើងនៅពេលដែល window ត្រូវបាន minimize
WINDOW_OPENED	កើតឡើងនៅពេលដែល window ត្រូវបានបើក

ទម្រង់ Constructor **របស់** WindowEvent **៖**

WindowEvent(Window src, int type)

Method **ដែលប្រើញឹកញាប់គឺ**getWindow() **វាឲ្យតម្លៃជា** object **នៃ** window **ដែលបង្កើតនូវ** event

Window getWindow()

៥. <u>អំពី Source នៃ Events</u>

ខាងក្រោមជា តារាងបង្ហាញពី components **សម្រាប់** user interface **ដែលអាចបង្កើត** event **។ លើសពីនេះ ក៏នៅមាន** component **មួយចំនួនទៀតដែលអាចបង្កើតនូវ** event **បានដែរដូចជា** applet **ជាដើម។**

Event Source	អធិប្បាយ
Button	បង្កើតនូវ action events ពេល button មួយត្រូវបានចុច
CheckBox	បង្កើតនូវ item events ពេល Checkbox ត្រូវបានជ្រើសយក ឬលុបបំបាត់ការជ្រើសយក
Choice	បង្កើតនូវ item events ពេល Choice ត្រូវបានផ្លាស់ប្តូរ
List	បង្កើតនូវ Action events ពេល item មួយត្រូវបានចុចពីរដងស្នួន ហើយបង្កើតនូវ item events ពេល item មួយត្រូវបានជ្រើសយក ឬលុបបំបាត់ការជ្រើសយក
MenuItem	បង្កើតនូវ Action events ពេល menu item មួយត្រូវបានជ្រើសរើសយក ហើយបង្កើតនូវ item events ពេល menu item ដែលមានលក្ខណៈ checkbox មួយត្រូវបានជ្រើសយក ឬលុបបំបាត់ការជ្រើសយក
Scollbar	បង្កើតនូវ Adjustment events នៅពេល scrollbar ត្រូវបានប្រើ
TextComponent	បង្កើតនូវ text event កាលណាអ្នកប្រើបានបញ្ចូលតួអក្សរ
Window	បង្កើតនូវ window event កាលណា window មួយស្ថិតក្នុងសភាពកំពុងមានសកម្មភាព, មិនមានសកម្មភាព បើក បិទ minimize maximize ឬ ចាកចេញ

៦. <u>អំពី Event Listener Interfaces</u>

ដូចយើងបានដឹងរួចមកហើយថាdelegation event model **មានពីរផ្នែកគឺ** sources **និង** listeners**។** Listeners **ត្រូវបានបង្កើតឡើងដោយ** interface **មួយឬច្រើន ដែលស្ថិតនៅក្នុង** package java.awt.event**។ កាលណា** event **មួយកើតឡើង** event source **ប្រើ** method **ដែលសមស្របកំណត់ដោយ** listener **និង ផ្តល់នូវ** event object **ជា** argument **របស់វា។**

ខាងក្រោមនេះជាតារាងបង្ហាញពីឈ្មោះlistener **ដែលប្រើញឹកញាប់៖**

Interface	អធិប្បាយ
ActionListener	មាន method មួយសម្រាប់ទទួល Action events
AdjustmentListener	មាន method មួយសម្រាប់ទទួល Adjustment events
ComponentListener	មាន methods បួន សម្រាប់សំគាល់នៅពេល component មួយត្រូវបាន

	បិទបាំង ផ្លាស់ទី ប្តូរទំហំ ឬបង្ហាញមកវិញ
ContainerListener	មាន methods ពីរ សម្រាប់សំគាល់នៅពេល component មួយត្រូវបានបន្ថែម ឬដកចេញ
FocusListener	មាន methods ពីរសម្រាប់សំគាល់នៅពេលដែល component មួយទទួល ឬ បាត់បង់ focus
ItemListener	មាន method មួយ ដើម្បីដឹងបាននៅពេលដែល item មួយបានប្រែប្រួល
KeyListener	មាន methods បី ដើម្បីដឹងថា key ចុចជាប់ ដកដៃមកវិញ key បានវាយ
MouseListener	មាន methods ប្រាំ ដើម្បីដឹងពីសកម្មភាព mouse ចុច , ចុចសង្កត់ជាប់ ព្រលែងពីការចុច រំកិលចូលទៅ component ឬចាកចេញពី component
MouseMotionListener	មាន method ពីរ ដើម្បីដឹងនៅពេល mouse ត្រូវបានចុចអូស ឬផ្លាស់ទី
TextListener	មាន method មួយដើម្បីបានតម្លៃរបស់ text បានប្រែប្រួល
WindowListener	មាន methods ប្រាំពីរ ដើម្បីបានសកម្មភាព window ទាំងអស់

៦.១ អំពី ActionListener interface

Interface **មាន** method **មួយឈ្មោះ** actionPerformed() **ដែលត្រូវបានប្រើនៅពេល** action event **កើតឡើង ។**

ទម្រង់របស់វា៖

```
void actionPerformed(ActionEvent ae)
```

៦.២ អំពី AdjustmentListener interface

Interface **មាន** method **មួយឈ្មោះ** adjustmentValueChanged() **ដែលត្រូវបានប្រើនៅពេល** adjustment event **កើតឡើង ។**

ទម្រង់របស់វា៖

```
void adjustmentValueChanged(AdjustmentEvent ae)
```

៦.៣ អំពី ComponentListener interface

Interface **មាន** methods **ចំនួនបួនដែលត្រូវបានប្រើនៅពេល**component **មួយត្រូវប្តូរទំហំ ផ្លាស់ទី បង្ហាញ ឬបិទបាំង ។**

ទម្រង់ទូទៅនៃ methods **ទាំងនោះ៖**

```
void componentResized(ComponentEvent ce)
void componentMoved(ComponentEvent ce)
void componentShown(ComponentEvent ce)
void componentHidden(ComponentEvent ce)
```

៦.៤ អំពី ContainerListener interface

Interface **មាន** methods **ចំនួន ២ នៅពេលដែលត្រូវការ** add **ធាតុចូល** container **យើងប្រើ** componentAdded **និងនៅពេលដែលត្រូវការលុប យើងប្រើ** componentRemoved()**។**

ទំរង់ទូទៅ៖

```
void componentAdded(ContainerEvent ce)
void componentRemoved(ContainerEvent ce)
```

៦.៥ <u>អំពី FocusListener interface</u>

Interface **មាន** methods **ចំនួន ២ ។ នៅពេល** component **មួយមាន** focus **របស់** keyboard **គេប្រើ** focusGained() **ហើយនៅពេល** component **មួយបាត់** focus **របស់** keyboard **គេប្រើ** focusLost()**។**

ទម្រង់ទូទៅ៖

```
void focusGained(FocusEvent fe)
void focusLost(FocusEvent fe)
```

៦.៦ <u>អំពី ItemListener interface</u>

Interface **មាន** method **មួយឈ្មោះ** itemStateChanged() **ដែលត្រូវបានប្រើនៅពេលសភាពលក្ខណៈរបស់** item **មួយផ្លាស់ប្តូរ ។**

ទម្រង់របស់វា៖

```
void itemStateChanged(ItemEvent ie)
```

៦.៧ <u>អំពី KeyListener interface</u>

Interface **មាន** methods **ចំនួន ៣ ។** keyPressed() **និង** keyReleased() **ប្រើនៅពេល** key **មួយត្រូវបានចុចសង្កត់និងព្រលែង។** keyTyped() **ត្រូវបានប្រើនៅពេលតួអក្សរមួយត្រូវបានវាយបញ្ចូល។**

ទម្រង់ទូទៅ៖

```
void keyPressed(KeyEvent ke)
void keyReleased (KeyEvent ke)
void keyTyped(KeyEvent ke)
```

៦.៨ <u>អំពី MouseListener interface</u>

Interface **មាន** methods **ចំនួន ៥ គឺ** mouseClicked(), mouseEntered(), mouseExited() mousePressed() **និង** mouseReleased() **។**

ទម្រង់ទូទៅ៖

```
void mouseClicked(MouseEvent me)
void mouseEntered(MouseEvent me)
void mouseExited(MouseEvent me)
void mousePressed(MouseEvent me)
void mouseReleased(MouseEvent me)
```

៦.៩ <u>អំពី MouseMotionListener interface</u>

Interface **មាន** methods **ចំនួន ២ ។** mouseDragged() **ត្រូវបានប្រើនៅពេលដែលគេចុចសង្កត់** mouse **ហើយរំកិលទៅដាក់ទីណាមួយនិង** mouseMoved() **ប្រើនៅពេលដែលយើងរំកិល**mouse**។**

ទម្រង់ទូទៅ៖

```
void mouseDragged(MouseEvent me)
void mouseMoved(MouseEvent me)
```

៦.១០ អំពី TextListener interface

Interface **មាន** methods **ចំនួន១ គឺ** textValueChanged()**។**

ទម្រង់ទូទៅ៖

```
void textValueChanged(TextEvent te)
```

៦.១១ អំពី WindowListener interface

Interface **មាន** methods **ចំនួន៧។** windowActivated(), windowDeactivated(), windowClosed(), windowOpened(), windowIconified(), windowDeiconified()**និង** windowClosing() **។**

ទម្រង់ទូទៅ៖

```
void windowActivated(WindowEvent we)
void windowDeactivated(WindowEvent we)
void windowClosed(WindowEvent we)
void windowClosing(WindowEvent we)
void windowIconified(WindowEvent we)
void windowDeiconified(WindowEvent we)
void windowOpened(WindowEvent we)
```

៧. ការប្រើប្រាស់ Delegation Event Model

ដើម្បីអនុវត្តតាមលំនាំdelegation event model **យើងត្រូវអនុវត្តនូវជំហានទាំងពីរដូចខាងក្រោម៖**

១- អនុវត្តនូវ interface **ដែលត្រូវគ្នានឹង** listener **ដូចនេះវានឹងទទួលបាននូវប្រភេទ** event **ដែលត្រូវការចាំបាច់**

២- ប្រើ code **ដើម្បីកត់ត្រា និងមិនកត់ត្រា(បើសិនជាត្រូវការ)នូវ** listener **ដូចទៅនឹងអ្នកទទួលកំណត់ត្រា** event

គួរចងចាំថា source **មួយអាចបង្កើតនូវ** event **ច្រើនប្រភេទ។** event **នីមួយៗត្រូវតែកត់ត្រាទុកដោយឡែកពីគ្នា។** object **មួយអាចកត់ត្រាទុកដើម្បីទទួល** events **ច្រើនប្រភេទបានដែរ ប៉ុន្តែវាត្រូវតែប្រើគ្រប់** interfaces **ដែលជាតម្រូវការ ដើម្បីទទួលបាន** events **ទាំងនេះ។**

៨. ការប្រើប្រាស់ Mouse Event

ដើម្បីអាចប្រើ mouse event **បាន យើងត្រូវតែអនុវត្តនូវ** interfaces **ឈ្មោះ** MouseListener **និង** MouseMotionListener **។**

ឧទាហរណ៍៖

```
import java.awt.*;
import java.awt.event.*;
class DemoMouseEvent extends Frame implements MouseListener,MouseMotionListener{
    String sms="";
```

```
String s="-";
String str="Mouse Events";
int mouseX=20,mouseY=20;
DemoMouseEvent(){
        super ("Demo Mouse Events!");
        setSize(300,250);
        addMouseListener(this);
        addMouseMotionListener(this);
        setVisible(true);
}
public void mouseClicked(MouseEvent me){
        sms="Mouse clicked,at x= " + me.getX() + " and Y = " + me.getY();
        setTitle(sms);
}
public void mouseEntered(MouseEvent me){
        mouseX=0;
        mouseY=10;
        sms="Mouse has Enetered";
        setTitle(sms);
}
public void mouseExited(MouseEvent me){
        mouseX=0;
        mouseY=10;
        sms="Mouse has Exited";
        setTitle(sms);
}
public void mousePressed(MouseEvent me){
        mouseX=me.getX();
        mouseY=me.getY();
        sms="Mouse has Pressed Down";
        setTitle(sms);
}
public void mouseReleased(MouseEvent me){
        mouseX=me.getX();
        mouseY=me.getY();
        sms="Mouse has Up";
        setTitle(sms);
}
public void mouseDragged(MouseEvent me){
        mouseX=me.getX();
```

```
            mouseY=me.getY();
            s="*";
            str="Mouse dragging at: " + mouseX + " , " + mouseY;
            repaint();
        }
        public void mouseMoved(MouseEvent me){
            str="Mouse has moved to " + me.getX() + " , "+me.getY();
            repaint();
        }
        // display sms in applet window at current x, y
        public void paint(Graphics g){
            g.drawString(s,mouseX,mouseY);
            g.drawString(str,mouseX,mouseY);
        }
        public static void main(String[] agr){
            new DemoMouseEvent();
        }
    }
```

ចូរពិនិត្យមើលឧទាហរណ៍ខាងលើ យើងឃើញថា class DemoMouseEvent ទទួលលក្ខណៈពី Frame class ហើយ implements ទៅលើ interface ពីរ គឺ MouseListener និង MouseMotionListener។ Frame គឺជា source ហើយក៏ជា listener សម្រាប់ event ទាំងនេះ។ វាអាចដំណើរការបានដោយសារ Component ជាអ្នកផ្តល់នូវ addMouseListener() និង addMouseMotionListener() method ហើយក៏ជា superclass របស់ Frame ដែរ។

នៅខាងក្នុង Constructor របស់ DemoMouseEvent កត់ត្រាខ្លួនវាជា listener សម្រាប់ mouse events ។ វាធ្វើឡើងដោយប្រើ addMouseListener() និង addMouseMotionListener() ។

ទម្រង់របស់វា៖

synchronized void addMouseListener(MouseListener ml)

synchronized void addMouseMotionListener(MouseMotionListener mml)

បន្ទាប់មក Frame អនុវត្តរាល់ methods ទាំងអស់កំណត់ដោយ MouseListener និង Mouse-MotionListener interface ។ Methods ទាំងនេះជាអ្នកប្រើ events ចំពោះ mouse events ប្រភេទផ្សេងៗ។

៩. <u>អំពី Adapter Classes</u>

Java 2 បានផ្តល់នូវលក្ខណៈពិសេសមួយដែលហៅថា Adapter class ដែលអាចជួយសម្រួលនូវការច្នៃប្រឌិតនៃការប្រើប្រាស់ event តាមស្ថានភាពជាក់ស្តែង ។ adapter class ផ្តល់នូវការអនុវត្តទទេនៃរាល់ methods ទាំងអស់មានក្នុង event listener interface ។ adapter class មានសារៈសំខាន់ណាស់នៅពេលដែលយើងចង់ទទួលនិងដំណើរការ events តែមួយចំនួនប៉ុណ្ណោះដែលប្រើដោយevent listener interface ពិសេស។ គេអាចកំណត់ class ថ្មីមួយដើម្បីធ្វើសកម្មភាពដូចនឹង event listener តាមរយៈការទទួលលក្ខណៈពី adapter class ហើយប្រើតែ events ដែលគេត្រូវការប៉ុណ្ណោះ។

ឧទាហរណ៍ MouseMotionListener **មាន** methods **ពីរគឺ** mouseDragged() **និង** mouseMoved()។ **សញ្ញាណនៃ** methods **ទទេ ទាំងនេះ គឺដូចទៅនឹងអ្វីដែលបានកំណត់នៅក្នុង** MouseMotionListener interface **ដែរ បើសិនជាយើងត្រូវការតែ** mousseDragged event **ទេ គឺយើងគ្រាន់តែទទួលលក្ខណៈពី** MouseMotionAdapter **ហើយប្រើតែ** method mouseDragged() **ជាការស្រេច។ វាអាចកាត់បន្ថយការសរសេរន្លៃ** mouseMoved() **បាន។**

តារាងខាងក្រោមបង្ហាញពី Adapter class និង interface ដែលត្រូវគ្នា

Adapter Class	Listener interface
ComponentAdapter	ComponentListener
ContainerAdapter	ContainerListener
FocusAdapter	FocusListener
KeyAdapter	KeyListener
MouseAdapter	MouseListener
MouseMotionAdapter	MouseMotionListener
WindowAdapter	WindowListener

ឧទាហរណ៍៖

```
import java.awt.*;
import java.awt.event.*;
class DemoAdapter extends Frame{
        DemoAdapter(){
                super("Demo adapter class.");
                setSize(300,300);
                addMouseListener(new MyMouseAdapter(this));
                addMouseMotionListener(new MyMouseMotionAdapter(this));
                setVisible(true);
        }
        public static void main(String[] agr){
                new DemoAdapter();
        }
}
class MyMouseAdapter extends MouseAdapter{
        DemoAdapter demoAdapter;
        public MyMouseAdapter (DemoAdapter demoAdapter){
                this.demoAdapter = demoAdapter;
        }
        public void mouseClicked(MouseEvent me){
                demoAdapter.setTitle("Mouse has been clicked.");
        }
}
```

```
class MyMouseMotionAdapter extends MouseMotionAdapter{
        DemoAdapter demoAdapter;
        public MyMouseMotionAdapter(DemoAdapter demoAdapter){
                this.demoAdapter=demoAdapter;
        }
        public void mouseDragged(MouseEvent me){
                demoAdapter.setTitle("Mouse dragged");
        }
}
```

១០. អំពី Adapter Inner Classes

នៅក្នុងករណីនេះ យើងនឹងលើកយកលក្ខណៈ inner class **ដែលយើងបានសិក្សាម្តងរួចមកហើយមកប្រើជាមួយនឹង** Adapter class **ដើម្បីជួយសម្រួលដល់ការសរសេរ**code **នៅពេលដែលយើងប្រើ** event adapter class **។**

ឧទាហរណ៍៖

```
import java.awt.*;
import java.awt.event.*;
class DemoAdapterInner extends Frame{
        DemoAdapterInner(){
                super("Demo Adapter inner!");
                setSize(400,300);
                addMouseListener(new MyMouseAdapter());
                addMouseMotionListener(new MyMouseMotionAdapter());
                setVisible(true);
        }
        public static void main(String[] agr){
                new DemoAdapterInner();
        }
        class MyMouseAdapter extends MouseAdapter{
                public void mouseClicked(MouseEvent me){
                        setTitle("Mouse clicked!");
                }
        }
        class MyMouseMotionAdapter extends MouseMotionAdapter{
                public void mouseDragged(MouseEvent me){
                        setTitle("Mouse Dragged!");
                }
        }
}
```

១១. អំពី Anonymous Adapter Inner Classes

Anonymous Adapter Inner Classes ជា class ដែលមិនមានការប្រើឈ្មោះ។ វាជួយសម្រួលដល់ការសរសេរ code នៃការប្រើប្រាស់ event ។

ឧទាហរណ៍៖

```
import java.awt.*;
import java.awt.event.*;
class DemoAnonymousAdapterInner extends Frame{
        DemoAnonymousAdapterInner(){
                super("Demo Anonymous Adapter Inner");
                setSize(400,350);
                addMouseListener(new MouseAdapter(){
                        public void mouseClicked(MouseEvent me){
                                setTitle("Mouse clicked!!!!");
                        }
                });
                addMouseMotionListener(new MouseMotionAdapter(){
                        public void mouseDragged(MouseEvent me){
                                setTitle("Mouse dragged!!!");
                        }
                });
                setVisible(true);
        }
